ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខ: ០២៤ សណន

# សេចក្តីណែនាំ

## ស្តីពី

## នីតិវិធីនៃការបោះឆ្នោតជ្រើសរើស
## ប្រធាន អនុប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត

អនុលោមមាត្រា១១ មាត្រា១៤ មាត្រា១៥ និងមាត្រា១៦នៃអនុក្រឹត្យលេខ១៩ អនក្រ.បក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការបង្កើតការិយាល័យប្រជាពលរដ្ឋនៅរដ្ឋបាលថ្នាក់ក្រោមជាតិ និងដើម្បីធានាឱ្យកិច្ចដំណើរការនៃការបោះឆ្នោតជ្រើសរើសប្រធាន អនុប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត ប្រព្រឹត្តទៅដោយរលូន ត្រឹមត្រូវ យុត្តិធម៌ សមធម៌ និងបរិយាប័ន្ន ក្រសួងមហាផ្ទៃសូមធ្វើការណែនាំដល់រដ្ឋបាលរាជធានី ខេត្ត ដូចខាងក្រោម៖

**១. ការរៀបចំគណៈកម្មាធិការបោះឆ្នោតជ្រើសរើសប្រធាន អនុប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត**

ប្រធាន អនុប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត ត្រូវជ្រើសរើសឡើងតាមរយៈការបោះឆ្នោតដោយគណៈកម្មាធិការបោះឆ្នោតជ្រើសរើសប្រធាន អនុប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត ដែលតទៅនេះហៅថា "**គណៈកម្មាធិការបោះឆ្នោត**" ។

**១.១. សមាសភាពគណៈកម្មាធិការបោះឆ្នោត**

គណៈកម្មាធិការបោះឆ្នោតមានសមាសភាពដូចខាងក្រោម៖

**ក). ចំពោះរដ្ឋបាលខេត្តដែលមានចំនួនសមាជិកក្រុមប្រឹក្សាតិចជាង ឬស្មើ១៩រូប៖**

| | |
|---|---|
| - ប្រធានក្រុមប្រឹក្សាខេត្ត | ប្រធាន |
| - សមាជិកក្រុមប្រឹក្សាខេត្តទាំងអស់ | សមាជិក |
| - ប្រធានសមាគមក្រុមប្រឹក្សាក្រុង ស្រុក ឃុំ សង្កាត់១រូប | សមាជិក |
| - តំណាងសភាពាណិជ្ជកម្មរាជធានី ខេត្ត៣រូប | សមាជិក |
| - តំណាងអង្គការសង្គមស៊ីវិល៣រូប | សមាជិក |

ឃ

**ខ). ចំពោះរដ្ឋបាលរាជធានី ខេត្តដែលមានចំនួនសមាជិកក្រុមប្រឹក្សាច្រើនជាង១៥រូប៖**

| | |
|---|---|
| - ប្រធានក្រុមប្រឹក្សារាជធានី ខេត្ត | ប្រធាន |
| - សមាជិកក្រុមប្រឹក្សារាជធានី ខេត្តទាំងអស់ | សមាជិក |
| - ប្រធានសមាគមក្រុមប្រឹក្សាខណ្ឌ សង្កាត់/ប្រធានសមាគមក្រុមប្រឹក្សាក្រុង ស្រុក ឃុំ សង្កាត់១រូប | សមាជិក |
| - តំណាងសភាពាណិជ្ជកម្មរាជធានី ខេត្ត៧រូប | សមាជិក |
| - តំណាងអង្គការសង្គមស៊ីវិល៧រូប | សមាជិក |

ការិយាល័យលេខាធិការក្រុមប្រឹក្សារាជធានី ខេត្ត ជាសេនាធិការនៃគណៈកម្មាធិការបោះឆ្នោត។

**១.២. ការចាត់តាំងតំណាងសភាពាណិជ្ជកម្មរាជធានី ខេត្ត**

ប្រធានក្រុមប្រឹក្សារាជធានី ខេត្ត ត្រូវធ្វើលិខិតទៅប្រធានសភាពាណិជ្ជកម្មរាជធានី ខេត្តដែលមានទីតាំងក្នុងដែនដីរដ្ឋបាលរាជធានី ខេត្តរបស់ខ្លួន ឬដែលមានវិសាលភាពគ្របដណ្តប់ក្នុងដែនដីរដ្ឋបាលរាជធានី ខេត្តរបស់ខ្លួន ដើម្បីចាត់តាំងតំណាងសភាពាណិជ្ជកម្មដែលជាសមាជិកសភាពាណិជ្ជកម្មតាមចំនួនដូចបានកំណត់ក្នុងចំណុច"ក" ឬចំណុច"ខ"នៃចំណុច១.១ខាងលើឱ្យធ្វើជាសមាជិកគណៈកម្មាធិការបោះឆ្នោត។ ក្នុងករណីសភាពាណិជ្ជកម្មរាជធានី ខេត្តមានវិសាលភាពគ្របដណ្តប់ក្នុងដែនដីរដ្ឋបាលរាជធានី ខេត្តលើសពីមួយ ប្រធានសភាពាណិជ្ជកម្មរាជធានី ខេត្តនោះអាចចាត់តាំងតំណាងដែលមានសមាសភាពដូចគ្នាដើម្បីធ្វើជាសមាជិកគណៈកម្មាធិការបោះឆ្នោតនៅរដ្ឋបាលរាជធានី ខេត្តទាំងនោះ។

ចំនួនតំណាងសភាពាណិជ្ជកម្មដែលបានចាត់តាំងនេះ ត្រូវមានស្ត្រីយ៉ាងតិចចំនួនមួយ(១)រូប លើកលែងតែសភាពាណិជ្ជកម្មរាជធានី ខេត្តនោះពុំមានសមាជិកជាស្ត្រី។

ការចាត់តាំងតំណាងសភាពាណិជ្ជកម្មរាជធានី ខេត្ត ត្រូវធ្វើឡើងតាមរយៈលិខិតជាផ្លូវការ។

**១.៣. ការជ្រើសរើសតំណាងអង្គការសង្គមស៊ីវិល**

ដំណើរការជ្រើសរើសតំណាងអង្គការសង្គមស៊ីវិល ត្រូវអនុវត្តតាមជំហានដូចខាងក្រោម៖

**ជំហានទី១៖ ការផ្សព្វផ្សាយអំពីការជ្រើសរើសតំណាងអង្គការសង្គមស៊ីវិល**

ប្រធានក្រុមប្រឹក្សារាជធានី ខេត្ត ត្រូវធ្វើលិខិតអញ្ជើញប្រធាន ឬតំណាងមួយ(១)រូបនៃអង្គការសង្គមស៊ីវិលជាតិទាំងអស់រួមមាន សមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដែលបានចុះបញ្ជីទទួលស្គាល់ដោយក្រសួងមហាផ្ទៃ និងមានការិយាល័យប្រតិបត្តិការ ព្រមទាំងធ្វើសកម្មភាពនៅក្នុងដែនដីរាជធានី ខេត្តរបស់ខ្លួន ដើម្បីចូលរួមកិច្ចប្រជុំផ្សព្វផ្សាយស្តីពីការជ្រើសរើសតំណាងអង្គការសង្គមស៊ីវិលជាតិសម្រាប់ធ្វើជាសមាជិកគណៈកម្មាធិការបោះឆ្នោត។

ក្នុងកិច្ចប្រជុំនេះ ប្រធានអង្គប្រជុំត្រូវធ្វើការពិភាក្សា និងកំណត់កាលបរិច្ឆេទនៃការបោះឆ្នោតជ្រើសរើសតំណាងអង្គការសង្គមស៊ីវិលជាតិដើម្បីធ្វើជាសមាជិកគណៈកម្មាធិការបោះឆ្នោត។

ប្រធានក្រុមប្រឹក្សារាជធានី ខេត្តជាអ្នកដឹកនាំ និងសម្របសម្រួលកិច្ចប្រជុំផ្សព្វផ្សាយអំពីការជ្រើសរើសតំណាងអង្គការសង្គមស៊ីវិលជាតិនេះ។

កិច្ចប្រជុំនេះត្រូវផ្សព្វផ្សាយអំពីខ្លឹមសារសំខាន់ៗដែលពាក់ព័ន្ធនឹង៖

- ការរៀបចំ និងការប្រព្រឹត្តទៅនៃការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត
- ការបង្កើតគណៈកម្មាធិការបោះឆ្នោត
- នីតិវិធីបោះឆ្នោតជ្រើសរើសតំណាងអង្គការសង្គមស៊ីវិលជាតិដើម្បីធ្វើជាសមាជិកគណៈកម្មាធិការបោះឆ្នោត។

**ជំហានទី២៖ កិច្ចប្រជុំបោះឆ្នោតជ្រើសរើសតំណាងអង្គការសង្គមស៊ីវិល**

ប្រធានក្រុមប្រឹក្សារាជធានី ខេត្ត ត្រូវធ្វើលិខិតអញ្ជើញតំណាងអង្គការសង្គមស៊ីវិលជាតិទាំងអស់ដែលបានចូលរួមក្នុងកិច្ចប្រជុំផ្សព្វផ្សាយស្តីពីការជ្រើសរើសតំណាងអង្គការសង្គមស៊ីវិល ដើម្បីចូលរួមបោះឆ្នោតជ្រើសរើសតំណាងរបស់ខ្លួន ឱ្យធ្វើជាសមាជិកគណៈកម្មាធិការបោះឆ្នោតយ៉ាងតិចបី(៣)ថ្ងៃនៃថ្ងៃធ្វើការមុនកាលបរិច្ឆេទនៃការបោះឆ្នោត។ នៅក្នុងខ្លឹមសារនៃលិខិតអញ្ជើញនេះ ប្រធានក្រុមប្រឹក្សារាជធានី ខេត្ត ត្រូវស្នើសុំឱ្យអង្គការសង្គមស៊ីវិលជាតិឧទ្ទេសនាមឈ្មោះបុគ្គលិកតំណាងអង្គការរបស់ខ្លួនជាលាយលក្ខណ៍អក្សរចំនួនមួយ(១)រូប ដើម្បីចូលរួមបោះឆ្នោតជ្រើសរើសតំណាងអង្គការសង្គមស៊ីវិលជាតិ។

បុគ្គលិកតំណាងអង្គការសង្គមស៊ីវិលជាតិ ដែលមានលិខិតឧទ្ទេសនាមឱ្យចូលរួមក្នុងកិច្ចប្រជុំបោះឆ្នោត ទើបមានសិទ្ធិបោះឆ្នោតជ្រើសរើសតំណាងអង្គការសង្គមស៊ីវិលជាតិ។

ប្រធានក្រុមប្រឹក្សារាជធានី ខេត្ត ជាអ្នកដឹកនាំ និងសម្របសម្រួលកិច្ចប្រជុំបោះឆ្នោតជ្រើសរើសតំណាងអង្គការសង្គមស៊ីវិល។

**ក). ការត្រៀមរៀបចំសម្រាប់ដំណើរការបោះឆ្នោត**

ដើម្បីឱ្យដំណើរការបោះឆ្នោតជ្រើសរើសតំណាងអង្គការសង្គមស៊ីវិលជាតិប្រព្រឹត្តទៅដោយរលូន ប្រធានក្រុមប្រឹក្សារាជធានី ខេត្ត ត្រូវចាត់ចែងឱ្យមានការត្រៀមរៀបចំនូវកិច្ចការមួយចំនួនដូចខាងក្រោម៖

- **ការរៀបចំតារាងបញ្ជីឈ្មោះបេក្ខជន៖** តារាងបញ្ជីឈ្មោះបេក្ខជនត្រូវដាក់តាំងបង្ហាញដល់អ្នកដែលមានសិទ្ធិបោះឆ្នោតទាំងអស់មុនការបោះឆ្នោត ដូចមានក្នុងទម្រង់គំរូទី១ភ្ជាប់ជាមួយនឹងសេចក្តីណែនាំនេះ
- **ការរៀបចំសន្លឹកឆ្នោត៖** សន្លឹកឆ្នោតត្រូវប្រើក្រដាសពណ៌សក្នុងទំហំសមស្រប ដែលមានលក្ខណៈដូចគ្នា និងមានទំហំប៉ុនៗគ្នា ព្រមទាំងមានបោះត្រារដ្ឋបាលរាជធានី ខេត្តតាមទម្រង់គំរូទី២ភ្ជាប់ជាមួយនឹងសេចក្តីណែនាំនេះ
- **ការរៀបចំហិបឆ្នោត៖** ហិបឆ្នោតត្រូវមានទំហំសមស្រប មានប្រឡោះសម្រាប់ដាក់សន្លឹកឆ្នោតចូល និងមានអក្សរសម្គាល់ថា **"ហិបឆ្នោត"**
- **ការរៀបចំបន្ទប់បោះឆ្នោត៖** បន្ទប់បោះឆ្នោតត្រូវរៀបចំនៅទីតាំងសមស្របមួយ ដើម្បីធានាការសម្ងាត់នៃការបោះឆ្នោត
- **ការត្រៀមរៀបចំសម្ភារនានា៖** សម្ភាររួមមាន តុ កៅអី ក្តារខៀន ក្រដាសផ្ទាំងធំ ហ្វឺត ស្កុត កន្ត្រៃ និងសម្ភារចាំបាច់ផ្សេងៗទៀត។

## ខ).ដំណើរការកិច្ចប្រជុំបោះឆ្នោត

### ខ.១. ការពិនិត្យវត្តមាននៃកិច្ចប្រជុំ

ការិយាល័យលេខាធិការក្រុមប្រឹក្សារាជធានី ខេត្ត បំពេញតួនាទីជាលេខាធិការនៃកិច្ចប្រជុំបោះឆ្នោតជ្រើសរើសតំណាងអង្គការសង្គមស៊ីវិលជាតិ។

មុនដំណើរការកិច្ចប្រជុំ លេខាធិការនៃកិច្ចប្រជុំត្រូវធ្វើសេចក្តីរាយការណ៍អំពីវត្តមានតំណាងអង្គការសង្គមស៊ីវិលជាតិដែលបានចូលរួមក្នុងកិច្ចប្រជុំ។ កិច្ចប្រជុំនេះអាចដំណើរការទៅបាន លុះត្រាតែមានចំនួនវត្តមានតំណាងអង្គការសង្គមស៊ីវិលជាតិលើសពីចំនួនតំណាងអង្គការសង្គមស៊ីវិលជាតិ ដែលបានកំណត់នៅក្នុងចំណុច"ក" ឬចំណុច"ខ"នៃចំណុច១.១ខាងលើ។

ក្នុងករណីដែលចំនួនវត្តមានតំណាងអង្គការសង្គមស៊ីវិលជាតិតិចជាង ឬស្មើនឹងចំនួនដែលបានកំណត់នៅក្នុងចំណុច"ក"ឬចំណុច"ខ"នៃចំណុច១.១ខាងលើ ប្រធានអង្គប្រជុំត្រូវផ្អាកដំណើរការកិច្ចប្រជុំ និងត្រូវរៀបចំកិច្ចប្រជុំបោះឆ្នោតជ្រើសរើសតំណាងអង្គការសង្គមស៊ីវិលសារជាថ្មីតាមនីតិវិធីដូចបានកំណត់ខាងលើ។

ប្រសិនបើកិច្ចប្រជុំបោះឆ្នោតជ្រើសរើសតំណាងអង្គការសង្គមស៊ីវិលលើកទី២នៅតែពុំមានតំណាងអង្គការសង្គមស៊ីវិលចូលរួមគ្រប់គ្រាន់ ប្រធានក្រុមប្រឹក្សារាជធានី ខេត្ត ត្រូវធ្វើរបាយការណ៍ជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដើម្បីផ្តល់យោបល់ដឹកនាំក្នុងការអនុវត្ត។

### ខ.២. ការជ្រើសរើសបេក្ខជនឈរឈ្មោះ

នៅក្នុងដំណើរការកិច្ចប្រជុំ ប្រធានអង្គប្រជុំ ត្រូវជម្រាបអំពីគោលបំណងនៃកិច្ចប្រជុំ និងត្រូវសម្របសម្រួលឱ្យតំណាងអង្គការសង្គមស៊ីវិលជាតិ ដែលបានចូលរួមក្នុងកិច្ចប្រជុំនេះឈរឈ្មោះជាបេក្ខជនដោយស្ម័គ្រចិត្ត។

ដើម្បីដំណើរការបោះឆ្នោតបាន ត្រូវមានបេក្ខជនឈរឈ្មោះបោះឆ្នោតលើសពីចំនួនតំណាងអង្គការសង្គមស៊ីវិលជាតិ ដែលត្រូវជ្រើសរើសជាសមាជិកនៃគណៈកម្មាធិការបោះឆ្នោតយ៉ាងតិចចំនួនមួយ(១)រូប។ ក្នុងចំណោមបេក្ខជនឈរឈ្មោះទាំងនេះ ប្រធានអង្គប្រជុំត្រូវលើកទឹកចិត្តឱ្យមានស្ត្រីឈរឈ្មោះឱ្យបានច្រើន។

ក្នុងករណីពុំមានបេក្ខជនស្ម័គ្រចិត្តឈរឈ្មោះគ្រប់ចំនួនតាមការកំណត់ខាងលើ ប្រធានអង្គប្រជុំត្រូវស្នើឱ្យតំណាងអង្គការសង្គមស៊ីវិលជាតិទាំងអស់ដែលបានចូលរួមក្នុងកិច្ចប្រជុំនេះ ឈរឈ្មោះជាបេក្ខជនសម្រាប់បោះឆ្នោតជ្រើសរើសតំណាងអង្គការសង្គមស៊ីវិលជាតិ ដើម្បីធ្វើជាសមាជិកគណៈកម្មាធិការបោះឆ្នោត។

### ខ.៣. ដំណើរការបោះឆ្នោត

ការបោះឆ្នោតជ្រើសរើសតំណាងអង្គការសង្គមស៊ីវិលជាតិត្រូវដំណើរការដូចខាងក្រោម៖

- ត្រូវសរសេរឈ្មោះបេក្ខជនឈរឈ្មោះទាំងអស់(ទម្រង់គំរូទី១)និងដាក់បង្ហាញឱ្យបានច្បាស់ដល់អ្នកចូលរួមទាំងអស់ដើម្បីងាយស្រួលក្នុងការបោះឆ្នោតជ្រើសរើស
- ប្រធានអង្គប្រជុំត្រូវចាត់លេខាធិការអង្គប្រជុំឱ្យអានឈ្មោះ និងបង្ហាញខ្លួនបេក្ខជនឈរឈ្មោះទាំងអស់ជូនអង្គប្រជុំ

- មុននឹងចែកសន្លឹកឆ្នោត ប្រធានអង្គប្រជុំ ត្រូវធ្វើការណែនាំអំពីគោលការណ៍ លក្ខខណ្ឌនានា និងរបៀបនៃការបោះឆ្នោតដូចខាងក្រោម៖
  + តំណាងអង្គការសង្គមស៊ីវិលនីមួយៗមានសិទ្ធិបោះឆ្នោតតែមួយសន្លឹកដូចៗគ្នា
  + ការបោះឆ្នោតនេះត្រូវធ្វើឡើងដោយសម្ងាត់
  + អ្នកបោះឆ្នោតម្នាក់ៗត្រូវសម្រេចជ្រើសរើសយកបេក្ខជនក្នុងចំនួនដូចបានកំណត់(៣រូប ឬ ៧រូប)
  + អ្នកបោះឆ្នោតម្នាក់ៗត្រូវធ្វើការបោះឆ្នោតនៅបន្ទប់បោះឆ្នោត ដោយសរសេរនៅលើសន្លឹកឆ្នោតនូវលេខរៀងបេក្ខជន ឬឈ្មោះបេក្ខជន ឬឈ្មោះអង្គការសង្គមស៊ីវិល ដែលខ្លួនពេញចិត្ត
  + សន្លឹកឆ្នោតមិនបានការមានដូចជា៖
    - ✓ មិនមែនជាសន្លឹកឆ្នោតដែលបានចែកជូន
    - ✓ គ្មានត្រារដ្ឋបាលរាជធានី ខេត្ត
    - ✓ សរសេរលេខរៀងបេក្ខជន ឬឈ្មោះបេក្ខជន ឬឈ្មោះអង្គការសង្គមស៊ីវិលតិចជាង ឬលើសពីចំនួនដែលបានកំណត់
    - ✓ មិនមានសរសេរគាំទ្រលើបេក្ខជនណាមួយ
    - ✓ សរសេរលេខរៀងបេក្ខជន ឬឈ្មោះបេក្ខជន ឬឈ្មោះអង្គការសង្គមស៊ីវិល ដែលមិនអាចកំណត់បានថាគាំទ្រដល់បេក្ខជនណាម្នាក់
    - ✓ មានសញ្ញាសម្គាល់
    - ✓ រហែក ឬប្រឡាក់ខូច។
  + អ្នកបោះឆ្នោតម្នាក់ៗ ត្រូវទម្លាក់សន្លឹកឆ្នោតរបស់ខ្លួនចូលទៅក្នុងហិបឆ្នោតមុននឹងចាកចេញពីកន្លែងបោះឆ្នោត ហើយត្រឡប់មកកាន់កន្លែងអង្គុយវិញ ដើម្បីរង់ចាំស្តាប់លទ្ធផលនៃការបោះឆ្នោត
  + បេក្ខជនដែលមានសំឡេងគាំទ្រច្រើនជាងគេ ត្រូវបានជ្រើសរើសជាសមាជិកគណៈកម្មាធិការបោះឆ្នោត
  + ក្នុងករណីបេក្ខជនដែលទទួលបានសំឡេងគាំទ្រស្មើគ្នារវាងបុរស និងស្ត្រី បេក្ខជនជាស្ត្រីត្រូវបានផ្តល់អាទិភាព
  + ក្នុងករណីបេក្ខជនដែលទទួលបានសំឡេងគាំទ្រស្មើគ្នាសុទ្ធតែបុរស ឬសុទ្ធតែស្ត្រី បេក្ខជនដែលមានអាយុច្រើនជាងគេត្រូវបានផ្តល់អាទិភាព
- បន្ទាប់មក ប្រធានអង្គប្រជុំត្រូវចាត់ចែងឱ្យចែកសន្លឹកឆ្នោតជូនអ្នកដែលមានសិទ្ធិបោះឆ្នោតទាំងអស់ម្នាក់មួយសន្លឹក ហើយទុករយៈពេលសមស្របមួយ ដើម្បីឱ្យអ្នកបោះឆ្នោតពិចារណា និងសម្រេចចិត្ត
- ប្រធានអង្គប្រជុំត្រូវចាត់ចែងឱ្យមានការបង្ហាញហិបឆ្នោតនៅចំពោះមុខអ្នកចូលរួមទាំងអស់
- ប្រធានអង្គប្រជុំត្រូវអញ្ជើញអ្នកបោះឆ្នោតម្តងម្នាក់ៗឡើងមកធ្វើការបោះឆ្នោត

- បន្ទាប់ពីអ្នកបោះឆ្នោតបានបោះឆ្នោតគ្រប់គ្នាហើយ ប្រធានអង្គប្រជុំត្រូវចាត់ចែងបើកហិបឆ្នោត និងធ្វើការរាប់សន្លឹកឆ្នោតនៅចំពោះមុខអ្នកចូលរួមទាំងអស់ដូចខាងក្រោម៖
  + យកសន្លឹកឆ្នោតចេញពីហិបឆ្នោតឱ្យអស់
  + រាប់សន្លឹកឆ្នោតដែលបានបោះទាំងអស់ (ចំនួនសរុបនៃសន្លឹកឆ្នោតដែលបានបោះ)
  + ពិនិត្យសន្លឹកឆ្នោត អានលេខរៀងបេក្ខជន ឬឈ្មោះបេក្ខជន ឬឈ្មោះអង្គការសង្គមស៊ីវិល ដែលមានសរសេរនៅលើសន្លឹកឆ្នោត និងបង្ហាញសន្លឹកឆ្នោតនោះដល់អង្គប្រជុំ ព្រមទាំងកត់ត្រាលទ្ធផលនៃការបោះឆ្នោត។ កិច្ចការនេះត្រូវអនុវត្តម្តងមួយសន្លឹកៗ រហូតដល់អស់សន្លឹកឆ្នោតដែលបានបោះ
  + ធ្វើចំណាត់ថ្នាក់បេក្ខជនទៅតាមសំឡេងឆ្នោតគាំទ្រ ដោយរៀបចំតាមលំដាប់លំដោយពីច្រើនមកតិច។ ក្នុងករណីបេក្ខជនទទួលបានសំឡេងគាំទ្រស្មើគ្នា ត្រូវអនុវត្តតាមគោលការណ៍ដូចខាងលើ។
- បន្ទាប់ពីរាប់សន្លឹកឆ្នោតរួច ប្រធានអង្គប្រជុំត្រូវចាត់ចែងឱ្យមានការរាយការណ៍ភ្លាមៗជូនអង្គប្រជុំអំពីលទ្ធផលនៃការបោះឆ្នោតដូចខាងក្រោម៖
  + សន្លឹកឆ្នោតដែលបានរៀបចំសរុបទាំងអស់ចំនួន.............................. សន្លឹក
  + សន្លឹកឆ្នោតដែលបានចែកជូនអ្នកបោះឆ្នោតសរុបចំនួន...................... សន្លឹក
  + សន្លឹកឆ្នោតដែលបានបោះដាក់ស្នែងសរុបចំនួន.............................. សន្លឹក
  + សន្លឹកឆ្នោតបានការចំនួន........................................................ សន្លឹក
  + សន្លឹកឆ្នោតមិនបានការចំនួន.................................................. សន្លឹក។
- ប្រធានអង្គប្រជុំត្រូវប្រកាសឈ្មោះបេក្ខជន ដែលបានជាប់ឆ្នោតតាមចំនួនដែលបានកំណត់នៅក្នុងចំណុច"ក" ឬចំណុច"ខ"នៃចំណុច១.១ខាងលើ និងប្រកាសឈ្មោះបេក្ខជនដែលជាប់ឆ្នោតបម្រុង។ បេក្ខជនជាប់ឆ្នោតបម្រុងត្រូវមានចំនួនយ៉ាងច្រើនស្មើនឹងចំនួនតំណាងអង្គការសង្គមស៊ីវិលដែលបានជាប់ឆ្នោត ហើយជាបេក្ខជនដែលទទួលបានសំឡេងគាំទ្រយ៉ាងតិចពីរសំឡេង។ ករណីបេក្ខជនជាប់ឆ្នោតបម្រុងមានចំនួនសំឡេងគាំទ្រស្មើគ្នាច្រើនជាងចំនួនដែលបានកំណត់ខាងលើ បេក្ខជនជាស្ត្រីត្រូវបានផ្តល់អាទិភាព។ ក្នុងករណីសំឡេងគាំទ្រស្មើគ្នាសុទ្ធតែជាបុរស ឬជាស្ត្រី បេក្ខជនដែលមានអាយុច្រើនជាងគេត្រូវបានផ្តល់អាទិភាព
- លទ្ធផលនៃការបោះឆ្នោតនេះត្រូវកត់ត្រានៅក្នុងកំណត់ហេតុត្រឹមត្រូវ និងច្បាស់លាស់។

### ១.៤. ការដាក់ចេញសេចក្តីសម្រេច

បន្ទាប់ពីទទួលបានសមាសភាពតំណាងសភាពាណិជ្ជកម្ម និងសមាសភាពតំណាងអង្គការសង្គមស៊ីវិល នាយករដ្ឋបាលរាជធានី ខេត្ត ត្រូវចាត់ចែងរៀបចំសេចក្តីព្រាងសេចក្តីសម្រេចស្តីពីការបង្កើតគណៈកម្មាធិការបោះឆ្នោតជ្រើសរើសប្រធាន អនុប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត ដើម្បីដាក់ជូនប្រធានក្រុមប្រឹក្សារាជធានី ខេត្ត ពិនិត្យ និងចុះហត្ថលេខា។ សេចក្តីសម្រេចនេះត្រូវបញ្ជូនមកក្រសួងមហាផ្ទៃចំនួនមួយ(១)ច្បាប់។

**១.៥. តួនាទី ភារកិច្ចរបស់គណៈកម្មាធិការបោះឆ្នោត**

គណៈកម្មាធិការបោះឆ្នោតមានតួនាទី ភារកិច្ចសំខាន់ៗដូចខាងក្រោម៖

- ធ្វើសេចក្តីជូនដំណឹងផ្សព្វផ្សាយអំពីការដាក់ពាក្យស្នើសុំឈរឈ្មោះជាបេក្ខជនសម្រាប់បោះឆ្នោតជ្រើសរើសប្រធាន អនុប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត
- រៀបចំបែងចែក និងទទួលពាក្យស្នើសុំឈរឈ្មោះជាបេក្ខជន
- សម្រាំងបេក្ខជនសម្រាប់ឈរឈ្មោះជាប្រធាន អនុប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត
- រៀបចំ និងបោះឆ្នោតជ្រើសរើសប្រធាន អនុប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត
- រៀបចំ និងបោះឆ្នោតអនុម័តទៅលើសំណើសុំដកហូតមុខតំណែងប្រធាន អនុប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត តាមសំណើរបស់សមាជិក១ភាគ៣នៃក្រុមប្រឹក្សារាជធានី ខេត្តសាមី ឬសមាជិក១ភាគ៣នៃគណៈកម្មាធិការបោះឆ្នោត។

**១.៦. របៀបរបបការងាររបស់គណៈកម្មាធិការបោះឆ្នោត**

គណៈកម្មាធិការបោះឆ្នោតអាចរៀបចំកិច្ចប្រជុំរបស់ខ្លួនទៅតាមការចាំបាច់ តាមសំណើរបស់ប្រធានគណៈកម្មាធិការបោះឆ្នោត ឬសមាជិក១ភាគ៣នៃគណៈកម្មាធិការបោះឆ្នោត។

កូរ៉ុមកិច្ចប្រជុំរបស់គណៈកម្មាធិការបោះឆ្នោត ត្រូវមានចំនួនលើសពីពាក់កណ្តាលនៃសមាជិកគណៈកម្មាធិការបោះឆ្នោតទាំងមូល លើកលែងតែកិច្ចប្រជុំបោះឆ្នោតជ្រើសរើសប្រធាន អនុប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្តដែលត្រូវអនុវត្តតាមចំណុច **២.៤(ខ.១)**នៃសេចក្តីណែនាំនេះ។

ប្រធានគណៈកម្មាធិការបោះឆ្នោតគឺជាអ្នកកោះប្រជុំ និងជាអធិបតីនៃអង្គប្រជុំរបស់គណៈកម្មាធិការបោះឆ្នោត។ ក្នុងករណីប្រធានអវត្តមាន ត្រូវផ្ទេរសិទ្ធិជាលាយលក្ខណ៍អក្សរឱ្យទៅសមាជិកណាមួយនៅក្នុងក្រុមប្រឹក្សារបស់ខ្លួន ស្របតាមបទប្បញ្ញត្តិមាត្រា៦៥នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌឱ្យទទួលជាប្រធានស្តីទី។

សេចក្តីសម្រេចដែលធ្វើឡើងនៅក្នុងកិច្ចប្រជុំរបស់គណៈកម្មាធិការបោះឆ្នោត ត្រូវមានសំឡេងអនុម័តលើសពីពាក់កណ្តាលនៃសមាជិកគណៈកម្មាធិការបោះឆ្នោតទាំងមូល លើកលែងតែការបោះឆ្នោតជ្រើសរើសប្រធាន អនុប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត។ ប្រសិនបើសំឡេងអនុម័តមានចំនួនស្មើគ្នា សំឡេងរបស់អធិបតីនៃអង្គប្រជុំមានឧត្តមានុភាព។

ការបោះឆ្នោតជ្រើសរើសប្រធាន អនុប្រធានការិយាល័យប្រជាពលរដ្ឋត្រូវអនុវត្តតាមនីតិវិធីដូចមានកំណត់ក្នុងចំណុច**២.៤(ខ.២.១)**នៃសេចក្តីណែនាំនេះ។

គ្រប់កិច្ចប្រជុំរបស់គណៈកម្មាធិការបោះឆ្នោត ត្រូវមានកំណត់ហេតុ ដែលរៀបចំដោយលេខាធិការនៃគណៈកម្មាធិការបោះឆ្នោត និងត្រូវចុះហត្ថលេខាដោយអធិបតីនៃអង្គប្រជុំ។

ប្រធានគណៈកម្មាធិការ ឬប្រធានស្តីទីមានសិទ្ធិប្រើប្រាស់ត្រារបស់រដ្ឋបាលរាជធានី ខេត្ត ក្នុងការបោះត្រាលើឯកសារនានា ដែលចុះហត្ថលេខាដោយប្រធានគណៈកម្មាធិការបោះឆ្នោត ឬប្រធានស្តីទី។

គណៈកម្មាធិការបោះឆ្នោតអាចដាក់ចេញបទបញ្ជាផ្ទៃក្នុង ឬនីតិវិធីអនុវត្តការងាររបស់ខ្លួនតាមការចាំបាច់។

**១.៧. អាណត្តិ និងការធ្វើសុពលភាពរបស់គណៈកម្មាធិការបោះឆ្នោត**

គណៈកម្មាធិការបោះឆ្នោតពុំមានកំណត់អាណត្តិការងារទេ។ គណៈកម្មាធិការនេះនឹងត្រូវបានធ្វើសុពលភាពឡើងវិញនៅពេលដែលមានសមាជិកណាម្នាក់បាត់បង់សមាជិកភាព។ រាល់សេចក្ដីសម្រេចធ្វើសុពលភាពសមាជិកគណៈកម្មាធិការបោះឆ្នោត ត្រូវបញ្ជូនមកក្រសួងមហាផ្ទៃចំនួនមួយ(១)ច្បាប់។

សមាជិកគណៈកម្មាធិការបោះឆ្នោតត្រូវបាត់បង់សមាជិកភាពពីសមាជិកគណៈកម្មាធិការនេះតាមករណីដូចខាងក្រោម៖

- សាមីខ្លួនទទួលមរណភាព
- សាមីខ្លួនសុំលាឈប់ជាលាយលក្ខណ៍អក្សរពីសមាជិកគណៈកម្មាធិការបោះឆ្នោត លើកលែងតែសមាជិកមកពីក្រុមប្រឹក្សារាជធានី ខេត្ត
- សាមីខ្លួនត្រូវតុលាការផ្ដន្ទាទោសពីបទមជ្ឈិមឬឧក្រិដ្ឋណាមួយ
- បាត់បង់សមាជិកភាពពីសមាជិកក្រុមប្រឹក្សារាជធានី ខេត្ត
- បាត់បង់មុខតំណែងជាប្រធានសមាគមក្រុមប្រឹក្សាក្រុង ស្រុក ឃុំ សង្កាត់/ប្រធានសមាគមក្រុមប្រឹក្សាខណ្ឌ សង្កាត់
- សមាជិកណាម្នាក់មកពីតំណាងសភាពាណិជ្ជកម្ម លែងជាសមាជិកសភាពាណិជ្ជកម្មក្នុងដែនសមត្ថកិច្ចរាជធានី ខេត្តសាមី ឬមានការស្នើសុំផ្លាស់ប្ដូរជាលាយលក្ខណ៍អក្សរនូវសមាជិកណាម្នាក់នៃសភាពាណិជ្ជកម្មដោយប្រធានសភាពាណិជ្ជកម្ម
- សមាជិកជាតំណាងអង្គការសង្គមស៊ីវិលណាម្នាក់ចប់អាណត្តិការងារនៅក្នុងអង្គការសង្គមស៊ីវិលនោះ ឬអង្គការសង្គមស៊ីវិលដែលសមាជិកនោះជាតំណាងបានបញ្ចប់បេសកកម្ម ឬផ្លាស់ប្ដូរការិយាល័យធ្វើការក្រៅដែនសមត្ថកិច្ចរាជធានី ខេត្តសាមីនីមួយៗ។

ការធ្វើសុពលភាពសមាជិកគណៈកម្មាធិការបោះឆ្នោតឡើងវិញត្រូវអនុវត្តតាមគោលការណ៍ និងនីតិវិធីដូចខាងក្រោម៖

- ក្នុងករណីសមាជិកណាម្នាក់មកពីក្រុមប្រឹក្សារាជធានី ខេត្ត មានការបាត់បង់សមាជិកភាពសមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ដែលត្រូវជំនួសថ្មី គឺជាសមាជិកគណៈកម្មាធិការបោះឆ្នោត
- ក្នុងករណីសមាជិកណាម្នាក់មកពីតំណាងសភាពាណិជ្ជកម្មមានការបាត់បង់សមាជិកភាពប្រធានក្រុមប្រឹក្សារាជធានី ខេត្តត្រូវស្នើសុំឱ្យប្រធានសភាពាណិជ្ជកម្មរាជធានី ខេត្តដែលមានទីតាំងក្នុងដែនដីរដ្ឋបាលរាជធានី ខេត្តរបស់ខ្លួនឬដែលមានវិសាលភាពគ្របដណ្ដប់ក្នុងដែនដីរដ្ឋបាលរាជធានី ខេត្តរបស់ខ្លួន ចាត់តាំងសមាជិកសភាពាណិជ្ជកម្មថ្មីមកធ្វើជាសមាជិកគណៈកម្មាធិការបោះឆ្នោតជំនួស
- ក្នុងករណីសមាជិកណាម្នាក់មកពីតំណាងអង្គការសង្គមស៊ីវិល មានការបាត់បង់សមាជិកភាពតំណាងអង្គការសង្គមស៊ីវិលដែលបានជាប់ឆ្នោតបម្រុងលេខរៀងលើគេនឹងត្រូវជ្រើសរើសជំនួសដោយស្វ័យប្រវត្តិជាសមាជិកគណៈកម្មាធិការបោះឆ្នោត។ ប្រសិនបើបេក្ខជនជាប់ឆ្នោតបម្រុងលេខរៀងលើគេមិនអាចជំនួសបាន បេក្ខជនជាប់ឆ្នោតបម្រុងបន្ទាប់នឹងត្រូវជ្រើសរើសជំនួស។



៥៤

ក្នុងករណីមិនមានបេក្ខជនជាប់ឆ្នោតបម្រុង ប្រធានគណៈកម្មាធិការបោះឆ្នោតត្រូវចាត់ចែងរៀបចំកិច្ចប្រជុំបោះឆ្នោតជ្រើសរើសតំណាងអង្គការសង្គមស៊ីវិលតាមចំនួនជាក់ស្តែងដើម្បីជំនួសសមាជិកដែលបានបាត់បង់សមាជិកភាព និងត្រូវជ្រើសរើសយកបេក្ខជនបម្រុងតាមនីតិវិធី និងលក្ខខណ្ឌដូចបានកំណត់ខាងលើ

- សេចក្តីព្រាងសេចក្តីសម្រេចស្តីពីការបង្កើតគណៈកម្មាធិការបោះឆ្នោតដែលត្រូវបានធ្វើសុពលភាពថ្មីនេះ ត្រូវដាក់ជូនប្រធានក្រុមប្រឹក្សារាជធានី ខេត្ត ពិនិត្យ និងចុះហត្ថលេខា។

**១.៨. កិច្ចប្រជុំដំបូងរបស់គណៈកម្មាធិការបោះឆ្នោត**

កិច្ចប្រជុំលើកដំបូងរបស់គណៈកម្មាធិការបោះឆ្នោត ត្រូវធ្វើឡើងក្នុងរយៈពេលមិនលើសពីដប់បួន (១៤)ថ្ងៃបន្ទាប់ពីថ្ងៃដែលបានដាក់ចេញនូវសេចក្តីសម្រេចបង្កើតគណៈកម្មាធិការបោះឆ្នោតនេះ។

កិច្ចប្រជុំដំបូងត្រូវរៀបចំឡើងដើម្បី៖

- ប្រកាសសមាសភាពគណៈកម្មាធិការបោះឆ្នោត
- ផ្សព្វផ្សាយអំពីតួនាទី ភារកិច្ច និងរបៀបរបបធ្វើការងាររបស់គណៈកម្មាធិការបោះឆ្នោត
- ផ្សព្វផ្សាយអំពីរចនាសម្ព័ន្ធ តួនាទី ភារកិច្ចរបស់ការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត
- ផ្សព្វផ្សាយអំពីនីតិវិធីនៃការបោះឆ្នោតជ្រើសរើសប្រធាន អនុប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត
- រៀបចំផែនការផ្សព្វផ្សាយ និងកំណត់កាលបរិច្ឆេទនៃការដាក់ពាក្យស្នើសុំឈរឈ្មោះជាបេក្ខជន ការសម្រាំងជ្រើសរើសបេក្ខជន និងការកំណត់កាលបរិច្ឆេទនៃការបោះឆ្នោតជ្រើសរើសប្រធាន អនុប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត។

**២. នីតិវិធីនៃការបោះឆ្នោតជ្រើសរើសប្រធាន អនុប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត**

ការបោះឆ្នោតជ្រើសរើសប្រធាន អនុប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត ត្រូវអនុវត្តតាមនីតិវិធីដូចខាងក្រោម៖

- ការប្រកាសជូនដំណឹងស្តីពីការបោះឆ្នោតជ្រើសរើសប្រធាន អនុប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត
- ការដាក់ពាក្យ និងការទទួលពាក្យស្នើសុំឈរឈ្មោះជាបេក្ខជន
- ការពិនិត្យ និងការសម្រាំងបេក្ខជន
- កិច្ចដំណើរការបោះឆ្នោត។

**២.១. ការប្រកាសជូនដំណឹងស្តីពីការបោះឆ្នោតជ្រើសរើសប្រធាន អនុប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត**

ប្រធានគណៈកម្មាធិការបោះឆ្នោត ត្រូវចាត់ចែងរៀបចំសេចក្តីជូនដំណឹងស្តីពីការបោះឆ្នោតជ្រើសរើសប្រធាន អនុប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត តាមទម្រង់គំរូទី៣ និងលក្ខខណ្ឌការងាររបស់ប្រធាន អនុប្រធានការិយាល័យប្រជាពលរដ្ឋតាមទម្រង់គំរូទី៤-ក និងទម្រង់ទី៤-ខ ដូចមានជូនភ្ជាប់ជាមួយសេចក្តីណែនាំនេះ។

សេចក្តីជូនដំណឹងនេះ ត្រូវបរិយាយឱ្យបានច្បាស់លាស់អំពី៖

- គោលបំណង និងគោលដៅនៃការបង្កើតការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត
- តួនាទី ភារកិច្ចរបស់ប្រធាន អនុប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត
- លក្ខខណ្ឌ និងលក្ខណសម្បត្តិបេក្ខជនសម្រាប់ឈរឈ្មោះ
- លក្ខខណ្ឌ និងលក្ខណសម្បត្តិបេក្ខជនដែលមិនអាចឈរឈ្មោះ
- ប្រាក់ឧបត្ថម្ភប្រចាំខែ និងផលប្រយោជន៍ផ្សេងៗទៀត
- កាលបរិច្ឆេទ និងទីកន្លែងនៃការទទួលពាក្យ
- ការផ្តល់អាទិភាព និងការលើកទឹកចិត្តដល់បេក្ខជនជាស្ត្រី ជនពិការ និងជនជាតិដើមភាគតិច។

សេចក្តីជូនដំណឹងស្តីពីការបោះឆ្នោតជ្រើសរើសប្រធាន អនុប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត និងលក្ខខណ្ឌការងារត្រូវធ្វើការផ្សព្វផ្សាយឱ្យបានទូលំទូលាយ ក្នុងរយៈពេលយ៉ាងតិចសាមសិប(៣០)ថ្ងៃគិតពីថ្ងៃចេញសេចក្តីជូនដំណឹង ដោយមានការបិទផ្សាយនៅលើក្តារព័ត៌មានរបស់រដ្ឋបាលរាជធានី ខេត្ត និងនៅទីសាធារណៈនានា និងផ្សព្វផ្សាយតាមបណ្តាញសារព័ត៌មាន គេហទំព័រ បណ្តាញសង្គម ឬមធ្យោបាយផ្សព្វផ្សាយព័ត៌មាននានាទៅតាមលទ្ធភាពនៃរដ្ឋបាលរាជធានី ខេត្តនីមួយៗ។

**២.២. ការដាក់ពាក្យ និងការទទួលពាក្យស្នើសុំឈរឈ្មោះជាបេក្ខជន**

ប្រធានគណៈកម្មាធិការបោះឆ្នោតត្រូវចាត់ចែង រៀបចំឱ្យមានទម្រង់ពាក្យស្នើសុំតាមទម្រង់គំរូទី៥ សម្រាប់បេក្ខជនដែលមានបំណងឈរឈ្មោះជាប្រធាន អនុប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត។

ប្រជាពលរដ្ឋទាំងពីរភេទដែលមានលក្ខខណ្ឌ និងលក្ខណសម្បត្តិសមស្របដូចមាត្រា១១នៃអនុក្រឹត្យលេខ ១៩អនក្រ.បក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការបង្កើតការិយាល័យប្រជាពលរដ្ឋនៅរដ្ឋបាលថ្នាក់ក្រោមជាតិ អាចឈរឈ្មោះជាបេក្ខជនប្រធានការិយាល័យប្រជាពលរដ្ឋក៏បាន ឬជាបេក្ខជនអនុប្រធានការិយាល័យប្រជាពលរដ្ឋក៏បាន ឬជាបេក្ខជនប្រធាន និងអនុប្រធានការិយាល័យប្រជាពលរដ្ឋក៏បាន។

ប្រជាពលរដ្ឋទាំងពីរភេទដែលមានបំណងឈរឈ្មោះជាបេក្ខជនប្រធាន និងឬអនុប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត ត្រូវមកទទួល និងដាក់ពាក្យស្នើសុំនៅការិយាល័យលេខាធិការក្រុមប្រឹក្សារាជធានី ខេត្តសាមី ដែលជាលេខាធិការដ្ឋាននៃគណៈកម្មាធិការបោះឆ្នោតតាមពេលម៉ោងធ្វើការរបស់រដ្ឋ។ ការចែកពាក្យស្នើសុំ ការដាក់ និងការទទួលពាក្យស្នើសុំពុំតម្រូវឱ្យមានបង់ថ្លៃសេវាឡើយ។

ការចែកពាក្យស្នើសុំ និងការទទួលពាក្យស្នើសុំត្រូវមានរយៈពេលយ៉ាងតិចសាមសិប(៣០)ថ្ងៃ បន្ទាប់ពីថ្ងៃចេញសេចក្តីជូនដំណឹងស្តីពីការបោះឆ្នោតជ្រើសរើសប្រធាន អនុប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត។

សំណុំឯកសារសម្រាប់ដាក់ពាក្យស្នើសុំឈរឈ្មោះជាបេក្ខជនរួមមាន៖

| | |
|---|---|
| - ពាក្យស្នើសុំចំនួន | ១ ច្បាប់ |
| - ប្រវត្តិរូបសង្ខេបមានបិទរូបថត៤x៦ចំនួន | ១ ច្បាប់ |
| - សេចក្តីចម្លងសំបុត្រកំណើត ឬបញ្ជាក់កំណើតចំនួន | ១ ច្បាប់ |
| - សៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅ ដែលថតចម្លងតាមច្បាប់ដើមចំនួន | ១ ច្បាប់ |
| - សញ្ញាបត្រ និងឬវិញ្ញាបនបត្រនានា ដែលថតចម្លងតាមច្បាប់ដើមចំនួន | ១ ច្បាប់ |
| - រូបថត៤x៦ចំនួន | ២ សន្លឹក |

នៅពេលទទួលពាក្យស្នើសុំ ការិយាល័យលេខាធិការក្រុមប្រឹក្សារាជធានី ខេត្ត ត្រូវកត់ត្រាឈ្មោះបេក្ខជន កាលបរិច្ឆេទនៃការទទួលពាក្យ និងហត្ថលេខារបស់បេក្ខជន។

ផុតរយៈពេលកំណត់នៃការទទួលពាក្យ ការិយាល័យលេខាធិការក្រុមប្រឹក្សារាជធានី ខេត្ត មិនត្រូវទទួលពាក្យរបស់បេក្ខជនឡើយ។

ការិយាល័យលេខាធិការក្រុមប្រឹក្សារាជធានី ខេត្ត ត្រូវធ្វើរបាយការណ៍អំពីការដាក់ និងការទទួលពាក្យស្នើសុំតាមទម្រង់គំរូទី៦ និងរៀបចំបញ្ជីឈ្មោះបេក្ខជនដែលបានដាក់ពាក្យស្នើសុំតាមទម្រង់គំរូទី៧ជូនប្រធានគណៈកម្មាធិការបោះឆ្នោត ដើម្បីចាត់ចែងបន្តតាមនីតិវិធី។

ក្នុងករណីបេក្ខជនដែលបានដាក់ពាក្យស្នើសុំឈរឈ្មោះជាប្រធាន ឬជាអនុប្រធានការិយាល័យប្រជាពលរដ្ឋមានចំនួនតិចជាងពីរ(២)រូប ប្រធានគណៈកម្មាធិការបោះឆ្នោតត្រូវរៀបចំប្រកាសជូនដំណឹងអំពីការពន្យារពេលនៃការដាក់ពាក្យ និងទទួលពាក្យស្នើសុំឈរឈ្មោះជាប្រធាន ឬនិងជាអនុប្រធាន។ ការពន្យារពេលនេះមិនត្រូវលើសពីរយៈពេលដប់ប្រាំ(១៥)ថ្ងៃនៃថ្ងៃធ្វើការឡើយ។

ផុតរយៈពេលនៃការពន្យារពេលនេះ ការិយាល័យលេខាធិការក្រុមប្រឹក្សា ត្រូវធ្វើរបាយការណ៍ និងបញ្ជីឈ្មោះបេក្ខជនជូនប្រធានគណៈកម្មាធិការបោះឆ្នោតតាមទម្រង់គំរូខាងលើ។ បញ្ជីឈ្មោះបេក្ខជននេះត្រូវបិទផ្សាយលើក្តារព័ត៌មានរបស់រដ្ឋបាលរាជធានី ខេត្ត ឬទីសាធារណៈ។ ប្រសិនបើចំនួនបេក្ខជនដាក់ពាក្យស្នើសុំឈរឈ្មោះជាប្រធាន ឬជាអនុប្រធាននៅតែមានចំនួនតិចជាង២រូបទៀត ប្រធានក្រុមប្រឹក្សាដែលជាប្រធានគណៈកម្មាធិការបោះឆ្នោត ត្រូវធ្វើរបាយការណ៍ជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដើម្បីផ្តល់យោបល់ដឹកនាំក្នុងការអនុវត្ត។

### ២.៣. ការពិនិត្យ និងការសម្រាំងបេក្ខជន

#### ក). ការបង្កើតក្រុមការងារពិនិត្យ និងសម្រាំងបេក្ខជន

ប្រធានគណៈកម្មាធិការបោះឆ្នោត ត្រូវដាក់ចេញនូវសេចក្តីសម្រេចបង្កើតក្រុមការងារទទួលបន្ទុកពិនិត្យ និងសម្រាំងបេក្ខជន។ ក្រុមការងារនេះមានសមាសភាពដូចខាងក្រោម៖

- ប្រធានក្រុមប្រឹក្សារាជធានី ខេត្ត — ប្រធាន
- សមាជិកគណៈកម្មាធិការបោះឆ្នោតមកពីតំណាងសភាពាណិជ្ជកម្ម១រូប — សមាជិក
- សមាជិកគណៈកម្មាធិការបោះឆ្នោតមកពីតំណាងអង្គការសង្គមស៊ីវិល១រូប — សមាជិក
- អភិបាលរងរាជធានី ខេត្ត១រូប — សមាជិក
- ប្រធានការិយាល័យលេខាធិការក្រុមប្រឹក្សារាជធានី ខេត្ត — លេខាធិការ

សមាជិកគណៈកម្មាធិការបោះឆ្នោតមកពីតំណាងសភាពាណិជ្ជកម្ម១រូប និងមកពីតំណាងអង្គការសង្គមស៊ីវិល១រូប ត្រូវបានចាត់តាំងដោយប្រធានគណៈកម្មាធិការបោះឆ្នោត។ អភិបាលរង១រូប ត្រូវបានចាត់តាំងដោយអភិបាលរាជធានី ខេត្ត។

#### ខ). ដំណើរការពិនិត្យ និងសម្រាំងបេក្ខជន

ក្រុមការងារពិនិត្យ និងសម្រាំងបេក្ខជន ត្រូវរៀបចំកិច្ចប្រជុំក្រុមការងាររបស់ខ្លួនយ៉ាងយូរ១សប្តាហ៍ក្រោយថ្ងៃឈប់ទទួលពាក្យស្នើសុំ ដើម្បីពិនិត្យ និងសម្រាំងបេក្ខជនដែលបានដាក់ពាក្យស្នើសុំឈរឈ្មោះជាប្រធាន ឬអនុប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត។

ការពិនិត្យ និងការសម្រាំងបេក្ខជននេះ ត្រូវធ្វើឡើងតាមរយៈការផ្ទៀងផ្ទាត់រវាងព័ត៌មាននានា ដែលមាននៅក្នុងពាក្យស្នើសុំ ប្រវត្តិរូបសង្ខេប និងឯកសារពាក់ព័ន្ធរបស់បេក្ខជននីមួយៗជាមួយនឹងលក្ខខណ្ឌ និងលក្ខណសម្បត្តិនៃបេក្ខជនដែលបានកំណត់ក្នុងមាត្រា១១នៃអនុក្រឹត្យលេខ ១៩ អនក្រ.បក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការបង្កើតការិយាល័យប្រជាពលរដ្ឋនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។ ក្នុងករណីចាំបាច់ ក្រុមការងារអាចស្នើសុំឱ្យបេក្ខជនណាមួយផ្តល់នូវឯកសារបន្ថែម ដើម្បីបញ្ជាក់អះអាងលើព័ត៌មានដែលបេក្ខជនបានបំពេញ ឬអាចស្វែងរកព័ត៌មានពីប្រភពផ្សេងៗទៀត ដើម្បីបញ្ជាក់លើព័ត៌មានដែលបេក្ខជនបានបំពេញ។

បេក្ខជនដែលបំពេញបាននូវគ្រប់លក្ខខណ្ឌ និងលក្ខណសម្បត្តិដូចបានកំណត់ខាងលើត្រូវបានសម្រាំងឱ្យឈរឈ្មោះជាបេក្ខជនសម្រាប់ការបោះឆ្នោតជ្រើសរើសជាប្រធាន ឬជាអនុប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត។ ក្នុងការពិនិត្យ និងការសម្រាំងបេក្ខជននេះ ត្រូវផ្អែកលើលក្ខខណ្ឌនិងលក្ខណសម្បត្តិដូចបានកំណត់ខាងលើ និងការឯកភាពគ្នាក្នុងក្រុមការងារ។ ក្នុងករណីមានសមាជិកក្រុមការងារមួយចំនួនមិនឯកភាពលើការសម្រាំងបេក្ខជននេះ ក្រុមការងារត្រូវសម្រេចដោយសំឡេងមតិភាគច្រើនដាច់ខាត។ ករណីមានសំឡេងស្មើគ្នា សំឡេងរបស់ប្រធានក្រុមការងារមានឧត្តមានុភាព។ លេខាធិការនៃក្រុមការងារពិនិត្យ និងសម្រាំងបេក្ខជនមិនមានសិទ្ធិផ្តល់ការឯកភាព ឬមិនឯកភាពលើការសម្រាំងបេក្ខជនសម្រាប់ឈរឈ្មោះបោះឆ្នោតជ្រើសរើសជាប្រធាន ឬជាអនុប្រធានការិយាល័យប្រជាពលរដ្ឋទេ។

បន្ទាប់ពីបញ្ចប់ការធ្វើសម្រាំងបេក្ខជនរួចហើយ ក្រុមការងារត្រូវរៀបចំបញ្ជីសម្រាំងបេក្ខជនតាមទម្រង់គំរូទី៨ ដើម្បីដាក់ជូនប្រធានគណៈកម្មាធិការបោះឆ្នោត និងត្រូវបិទផ្សាយនៅលើក្តារព័ត៌មានរបស់រដ្ឋបាលរាជធានី ខេត្ត និងនៅទីសាធារណៈនានាយ៉ាងតិចប្រាំពីរ(៧)ថ្ងៃនៃថ្ងៃធ្វើការ ដើម្បីជូនដំណឹងដល់បេក្ខជនដែលបានដាក់ពាក្យអាចធ្វើការតវ៉ាទៅលើលទ្ធផលនៃការសម្រាំងនេះ។ ការតវ៉ាត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរដោយមានកម្មវត្ថុ និងមូលហេតុច្បាស់លាស់ ហើយត្រូវដាក់ជូនប្រធានគណៈកម្មាធិការបោះឆ្នោតក្នុងកំឡុងពេលនៃការបិទផ្សាយនេះ។ ប្រធានគណៈកម្មាធិការបោះឆ្នោតត្រូវរៀបចំឱ្យមានទីកន្លែង និងមន្ត្រីសម្រាប់ទទួលបណ្តឹងតវ៉ាទាំងនោះ។ ក្នុងករណីមានបណ្តឹងតវ៉ាពីបេក្ខជនណាមួយ ប្រធានគណៈកម្មាធិការបោះឆ្នោតត្រូវចាត់ឱ្យក្រុមការងារពិនិត្យ និងសម្រាំងបេក្ខជនធ្វើការប្រជុំពិនិត្យមើលឡើងវិញ។ លទ្ធផលនៃការពិនិត្យមើលឡើងវិញរបស់ក្រុមការងារជាលទ្ធផលចុងក្រោយ និងត្រូវផ្តល់ព័ត៌មានត្រឡប់ជូនដល់អ្នកប្តឹងតវ៉ាដោយមានបញ្ជាក់អំពីមូលហេតុច្បាស់លាស់ ព្រមទាំងត្រូវធ្វើសេចក្តីរាយការណ៍ជូនកិច្ចប្រជុំរបស់គណៈកម្មាធិការបោះឆ្នោត។

ក្នុងករណីបេក្ខជនដែលបានជាប់សម្រាំងសម្រាប់ឈរឈ្មោះជាប្រធាន ឬជាអនុប្រធានការិយាល័យប្រជាពលរដ្ឋមានចំនួនតិចជាង២រូប ប្រធានគណៈកម្មាធិការបោះឆ្នោតត្រូវចាត់ចែងឱ្យមានការប្រកាសជូនដំណឹងស្តីពីការជ្រើសរើសមុខតំណែងដែលខ្វះនោះបន្ថែមទៀត។ ការប្រកាសជូនដំណឹងនេះត្រូវមានរយៈពេលយ៉ាងយូរដប់ប្រាំ(១៥)ថ្ងៃនៃថ្ងៃធ្វើការ។ ការពិនិត្យ និងការសម្រាំងបេក្ខជនបន្ថែមនេះត្រូវអនុវត្តតាមនីតិវិធីដូចបានអនុវត្តលើកទី១។ ប្រសិនបើការសម្រាំងលើកទី២បន្ថែមនេះនៅតែមិនមានចំនួនបេក្ខជនគ្រប់តាមគោលការណ៍កំណត់ទៀតនោះ ប្រធានក្រុមប្រឹក្សាដែលជាប្រធានគណៈកម្មាធិការបោះឆ្នោតត្រូវធ្វើរបាយការណ៍ជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដើម្បីផ្តល់យោបល់ដឹកនាំក្នុងការអនុវត្ត។

### ២.៤. កិច្ចដំណើរការបោះឆ្នោត

#### ក). ការត្រៀមរៀបចំសម្រាប់ដំណើរការបោះឆ្នោត

ដើម្បីឱ្យដំណើរការបោះឆ្នោតជ្រើសរើសប្រធាន អនុប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត ប្រព្រឹត្តទៅដោយរលូន ប្រធានគណៈកម្មាធិការបោះឆ្នោត ត្រូវចាត់ចែងឱ្យមានការត្រៀមរៀបចំនូវកិច្ចការមួយចំនួនដូចខាងក្រោម៖

- **ការរៀបចំតារាងបញ្ជីឈ្មោះបេក្ខជន៖** តារាងបញ្ជីឈ្មោះបេក្ខជនត្រូវដាក់តាំងបង្ហាញដល់អ្នកដែលមានសិទ្ធិបោះឆ្នោតទាំងអស់មុនការបោះឆ្នោត ដូចមានក្នុងទម្រង់គំរូទី៩ភ្ជាប់ជាមួយនឹងសេចក្តីណែនាំនេះ
- **ការរៀបចំសន្លឹកឆ្នោត៖** សន្លឹកឆ្នោតត្រូវបានបោះពុម្ពរួចជាស្រេចដែលមានទម្រង់ និងទំហំដូចគ្នាដោយមានរូបថត មានឈ្មោះបេក្ខជនតាមលំដាប់តួអក្សរនៃឈ្មោះរបស់បេក្ខជននីមួយៗ មានបញ្ជាក់អំពីភេទ និងអាយុរបស់បេក្ខជននីមួយៗ ព្រមទាំងមានបោះត្រារដ្ឋបាលរាជធានី ខេត្តសាមីនៅខ្នងសន្លឹកឆ្នោតតាមទម្រង់គំរូទី១០។ សន្លឹកឆ្នោតសម្រាប់បោះឆ្នោតជ្រើសរើសប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត ត្រូវរៀបចំឡើងដាច់ដោយឡែកពីសន្លឹកឆ្នោតសម្រាប់បោះឆ្នោតជ្រើសរើសអនុប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត
- **ការរៀបចំហិបឆ្នោត៖** ហិបឆ្នោតត្រូវមានទំហំសមស្រប មានប្រឡោះសម្រាប់ដាក់សន្លឹកឆ្នោតចូល និងមានអក្សរសម្គាល់ថា **"ហិបឆ្នោត"**
- **ការរៀបចំបន្ទប់បោះឆ្នោត៖** បន្ទប់បោះឆ្នោតត្រូវរៀបចំនៅទីតាំងសមស្របមួយ ដើម្បីធានាការសម្ងាត់នៃការបោះឆ្នោត
- **ការត្រៀមរៀបចំសម្ភារនានា៖** សម្ភាររួមមាន ក្តារខៀន ក្រដាសផ្ទាំងធំ ហ្វឺត ស្កុត កន្ត្រៃ និងសម្ភារចាំបាច់ផ្សេងៗទៀត
- **ការរៀបចំលិខិតអញ្ជើញប្រជុំ៖** លិខិតអញ្ជើញប្រជុំបោះឆ្នោតជ្រើសរើសប្រធាន អនុប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត ត្រូវរៀបចំឡើងដោយការិយាល័យលេខាធិការក្រុមប្រឹក្សា និងត្រូវចុះហត្ថលេខាដោយប្រធានគណៈកម្មាធិការបោះឆ្នោត។ លិខិតអញ្ជើញត្រូវចែកជូនដល់សមាជិកគណៈកម្មាធិការបោះឆ្នោតយ៉ាងតិចបី(៣)ថ្ងៃ មុនកិច្ចប្រជុំដោយភ្ជាប់មកជាមួយនូវបញ្ជីសម្រាំងបេក្ខជនឈរឈ្មោះបោះឆ្នោត និងប្រវត្តិរូបសង្ខេបរបស់បេក្ខជនម្នាក់ៗ។ការិយាល័យលេខាធិការក្រុមប្រឹក្សាក៏ត្រូវអញ្ជើញបេក្ខជន ដែលមានឈ្មោះក្នុងបញ្ជីសម្រាំងឱ្យចូលរួមក្នុងកិច្ចប្រជុំបោះឆ្នោតជ្រើសរើសប្រធាន អនុប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្តផងដែរ។

#### ខ). ដំណើរការកិច្ចប្រជុំបោះឆ្នោត

#### ខ.១. ការពិនិត្យកូរ៉ុម

ការិយាល័យលេខាធិការក្រុមប្រឹក្សា ដែលជាសេនាធិការឱ្យគណៈកម្មាធិការបោះឆ្នោតត្រូវធ្វើសេចក្តីរាយការណ៍អំពីចំនួនសមាជិកគណៈកម្មាធិការបោះឆ្នោតដែលមានវត្តមាន និងអវត្តមានក្នុងកិច្ចប្រជុំ (ដោយបញ្ជាក់អំពីមូលហេតុនៃអវត្តមាន)។ កិច្ចប្រជុំបោះឆ្នោតជ្រើសរើសប្រធាន អនុប្រធានការិយាល័យ



ឩ

ប្រជាពលរដ្ឋរាជធានី ខេត្ត អាចដំណើរការទៅបាន លុះត្រាតែមានចំនួនកូរ៉ុមចាប់ពីពីរភាគបី(២/៣)នៃសមាជិកគណៈកម្មាធិការបោះឆ្នោត។ ក្នុងករណីពុំមានកូរ៉ុមគ្រប់គ្រាន់ទេ ប្រធានគណៈកម្មាធិការបោះឆ្នោតត្រូវប្រកាសលើកកិច្ចប្រជុំទៅពេលវេលាណាមួយសមស្រប។

**ខ.២. ការបើកកិច្ចប្រជុំ**

ប្រធានគណៈកម្មាធិការបោះឆ្នោតដែលជាអធិបតីអង្គប្រជុំត្រូវមានមតិស្វាគមន៍បើកកិច្ចប្រជុំដោយជម្រាបអំពីគោលបំណងនៃកិច្ចប្រជុំ អំពីលទ្ធផលនៃការដាក់ពាក្យ និងទទួលពាក្យស្នើសុំឈរឈ្មោះជាបេក្ខជន អំពីលទ្ធផលនៃការពិនិត្យ និងការសម្រាំងបេក្ខជន ព្រមទាំងណែនាំអំពីគោលការណ៍នានា និងនីតិវិធីនៃការបោះឆ្នោតដូចខាងក្រោម៖

**ខ.២.១. គោលការណ៍**

- ការបោះឆ្នោតជ្រើសរើសប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត ត្រូវធ្វើឡើងដាច់ដោយឡែកពីការបោះឆ្នោតជ្រើសរើសអនុប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត។ ការបោះឆ្នោតជ្រើសរើសប្រធាន និងអនុប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត អាចធ្វើឡើងក្នុងកិច្ចប្រជុំជាមួយគ្នាក៏បាន ឬកិច្ចប្រជុំដាច់ដោយឡែកពីគ្នាក៏បាន
- សមាជិកគណៈកម្មាធិការបោះឆ្នោតរាជធានី ខេត្តម្នាក់ៗមានសិទ្ធិបោះឆ្នោតតែមួយសំឡេងសម្រាប់ជ្រើសរើសប្រធានការិយាល័យប្រជាពលរដ្ឋ និងមួយសំឡេងសម្រាប់ជ្រើសរើសអនុប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត
- ការបោះឆ្នោតនេះត្រូវធ្វើឡើងដោយសម្ងាត់
- អ្នកបោះឆ្នោតម្នាក់ៗត្រូវសម្រេចជ្រើសរើសយកបេក្ខជនមួយ(១)រូប សម្រាប់មុខតំណែងប្រធាន ឬអនុប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត៖
  - **ប្រធានការិយាល័យប្រជាពលរដ្ឋ៖** បេក្ខជនដែលបានទទួលសំឡេងគាំទ្រលើសពីពាក់កណ្តាលនៃសមាជិកគណៈកម្មាធិការបោះឆ្នោតទាំងមូល ត្រូវបានជ្រើសរើសជាប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត
  - **អនុប្រធានការិយាល័យប្រជាពលរដ្ឋ៖** បេក្ខជនដែលបានទទួលសំឡេងគាំទ្រលើសពីពាក់កណ្តាលនៃសមាជិកគណៈកម្មាធិការបោះឆ្នោតទាំងមូល ត្រូវបានជ្រើសរើសជាអនុប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត
- ក្នុងករណីបេក្ខជនដែលទទួលបានសំឡេងគាំទ្រច្រើនជាងគេនៃការបោះឆ្នោតជ្រើសរើសប្រធាន ឬអនុប្រធានការិយាល័យប្រជាពលរដ្ឋ ប៉ុន្តែសំឡេងគាំទ្រនោះតិចជាងឬស្មើពាក់កណ្តាលនៃសមាជិកគណៈកម្មាធិការបោះឆ្នោតទាំងមូល ប្រធានគណៈកម្មាធិការបោះឆ្នោតត្រូវរៀបចំការបោះឆ្នោតជាលើកទី២ភ្លាមក្នុងចំណោមបេក្ខជនពីរ(២)រូប ដែលទទួលបានសំឡេងគាំទ្រច្រើនជាងគេ។ ករណីបេក្ខជនដែលទទួលបានសំឡេងគាំទ្រច្រើនជាងគេមានចំនួនលើសពីពីរ(២)រូប



ណៃ

បេក្ខជនទាំងនោះនឹងត្រូវដាក់ឱ្យឈរឈ្មោះបោះឆ្នោតជាលើកទី២។ បេក្ខជនដែលទទួលបានសំឡេងគាំទ្រលើសពីពាក់កណ្ដាលនៃកូរ៉ុមនៃកិច្ចប្រជុំសម្រាប់ការបោះឆ្នោតលើកទី២នេះ ត្រូវបានជាប់ឆ្នោតជាប្រធាន ឬអនុប្រធានការិយាល័យប្រជាពលរដ្ឋ។ ប្រសិនបើការបោះឆ្នោតលើកទី២នេះនៅតែមិនអាចរកបាននូវបេក្ខជន ដែលមានសំឡេងគាំទ្រលើសពីពាក់កណ្ដាលនៃកូរ៉ុមនៃកិច្ចប្រជុំ ប្រធានគណៈកម្មាធិការបោះឆ្នោតត្រូវចាត់ចែងរៀបចំឱ្យមានការប្រកាសជ្រើសរើសបេក្ខជនឡើងវិញតាមនីតិវិធី និងជំហាននានាដូចបានកំណត់ក្នុងចំណុច២នៃសេចក្ដីណែនាំនេះ

- កិច្ចប្រជុំបោះឆ្នោតជ្រើសរើសប្រធាន អនុប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្តត្រូវធ្វើឡើងជាសាធារណៈដែលអនុញ្ញាតឱ្យអ្នកពាក់ព័ន្ធនានាចូលរួមសង្កេតការណ៍ក្នុងកិច្ចប្រជុំនេះបាន។

### ៥.២.២. នីតិវិធីបោះឆ្នោត

- អ្នកបោះឆ្នោតម្នាក់ៗត្រូវគូសសញ្ញា "✓" នៅលើសន្លឹកឆ្នោតត្រង់កូឡោន **"បោះឆ្នោតគាំទ្រ"** នៅជួរបន្ទាត់នៃឈ្មោះបេក្ខជន
- អ្នកបោះឆ្នោតម្នាក់ៗ ត្រូវទៅកាន់បន្ទប់បោះឆ្នោតដើម្បីបោះឆ្នោតគាំទ្របេក្ខជនណាម្នាក់នៅលើសន្លឹកឆ្នោតដែលបានចែកជូន
- អ្នកបោះឆ្នោតម្នាក់ៗត្រូវទម្លាក់សន្លឹកឆ្នោតរបស់ខ្លួនចូលទៅក្នុងហិបឆ្នោត មុននឹងចាកចេញពីកន្លែងបោះឆ្នោតហើយត្រឡប់មកកាន់កន្លែងអង្គុយវិញដើម្បីរង់ចាំស្ដាប់លទ្ធផលនៃការបោះឆ្នោត
- សន្លឹកឆ្នោតដែលចាត់ទុកថាមិនបានការគឺជាសន្លឹកឆ្នោតដែល៖
  - + មិនមែនជាសន្លឹកឆ្នោតដែលបានចែកជូន
  - + គ្មានត្រារដ្ឋបាលរាជធានី ខេត្ត
  - + គូសគាំទ្របេក្ខជនលើសពី១រូប
  - + គូសក្រៅកូឡោនបោះឆ្នោតគាំទ្រ
  - + មិនមានគំនូសគាំទ្របេក្ខជនណាម្នាក់
  - + មានគំនូសដែលមិនអាចកំណត់បានថាគាំទ្រដល់បេក្ខជនណាម្នាក់
  - + មានសញ្ញាសម្គាល់
  - + រហែក ឬប្រឡាក់ខូច។

## ៥.៣. ដំណើរការបោះឆ្នោត

ការបោះឆ្នោតជ្រើសរើសប្រធាន ឬអនុប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្តត្រូវដំណើរការដូចខាងក្រោម៖

- **ការបង្ហាញតារាងបញ្ជីឈ្មោះបេក្ខជន និងបេក្ខជនឈរឈ្មោះបោះឆ្នោត៖** ប្រធានអង្គប្រជុំត្រូវចាត់លេខាធិការអង្គប្រជុំឱ្យធ្វើការបង្ហាញបញ្ជីឈ្មោះបេក្ខជនឈរឈ្មោះបោះឆ្នោតជាប្រធាន ឬអនុប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត ដល់សមាជិកគណៈកម្មាធិការបោះឆ្នោត។

លេខាធិការអង្គប្រជុំត្រូវអានលេខរៀង ឈ្មោះបេក្ខជន អាយុ ភេទ ទីលំនៅបច្ចុប្បន្ន កម្រិតវប្បធម៌ និងបទពិសោធការងាររបស់បេក្ខជន ព្រមទាំងស្នើឱ្យបេក្ខជនម្នាក់ៗបង្ហាញខ្លួនជូនដល់អង្គប្រជុំ

- **ការចែកសន្លឹកឆ្នោត៖** បន្ទាប់ពីបង្ហាញតារាងបញ្ជីឈ្មោះបេក្ខជន និងបេក្ខជនដែលបានឈរឈ្មោះបោះឆ្នោតរួចមក ប្រធានអង្គប្រជុំត្រូវចាត់ចែងឱ្យចែកសន្លឹកឆ្នោតជូនសមាជិកគណៈកម្មាធិការបោះឆ្នោតដែលមានវត្តមានម្នាក់មួយសន្លឹក ហើយទុករយៈពេលសមស្របមួយដើម្បីធ្វើការពិចារណា និងសម្រេចចិត្ត
- **ការបោះឆ្នោត៖** ប្រធានអង្គប្រជុំត្រូវចាត់ចែងឱ្យមានការបង្ហាញហិបឆ្នោតនៅចំពោះមុខអ្នកចូលរួមទាំងអស់។ បន្ទាប់មក លេខាធិការអង្គប្រជុំត្រូវអញ្ជើញប្រធានគណៈកម្មាធិការបោះឆ្នោតឡើងបោះឆ្នោតមុនគេ និងសមាជិកគណៈកម្មាធិការបោះឆ្នោតម្តងម្នាក់ៗឡើងមកធ្វើការបោះឆ្នោតជាបន្តបន្ទាប់
- **ការរាប់សន្លឹកឆ្នោត៖** បន្ទាប់ពីសមាជិកគណៈកម្មាធិការបោះឆ្នោតបានបោះឆ្នោតរួចហើយ ប្រធានអង្គប្រជុំត្រូវចាត់ចែងបើកហិបឆ្នោត និងធ្វើការរាប់សន្លឹកឆ្នោតនៅចំពោះមុខអ្នកចូលរួមទាំងអស់ដូចខាងក្រោម៖
  + យកសន្លឹកឆ្នោតចេញពីហិបឆ្នោតឱ្យអស់
  + រាប់សន្លឹកឆ្នោតដែលបានបោះទាំងអស់ (ចំនួនសរុបនៃសន្លឹកឆ្នោតដែលបានបោះ)
  + ពិនិត្យសន្លឹកឆ្នោត អានឈ្មោះបេក្ខជនដែលទទួលបានការបោះឆ្នោតគាំទ្រ និងបង្ហាញសន្លឹកឆ្នោតនោះដល់អង្គប្រជុំ ព្រមទាំងកត់ត្រាលទ្ធផលនៃការបោះឆ្នោត។ កិច្ចការនេះត្រូវអនុវត្តម្តងមួយសន្លឹកៗ រហូតដល់អស់សន្លឹកឆ្នោតដែលបានបោះ
  + បូកសរុបលទ្ធផលសំឡេងគាំទ្របេក្ខជននីមួយៗ
- **ការរាយការណ៍អំពីលទ្ធផលនៃការបោះឆ្នោត៖** បន្ទាប់ពីរាប់សន្លឹកឆ្នោតរួច ប្រធានអង្គប្រជុំត្រូវចាត់ចែងឱ្យមានការរាយការណ៍ភ្លាមៗជូនអង្គប្រជុំអំពីលទ្ធផលនៃការបោះឆ្នោតដូចខាងក្រោម៖
  + សន្លឹកឆ្នោតដែលបានរៀបចំសរុបទាំងអស់ចំនួន............................. សន្លឹក
  + សន្លឹកឆ្នោតដែលបានចែកជូនអ្នកបោះឆ្នោតសរុបចំនួន..................... សន្លឹក
  + សន្លឹកឆ្នោតដែលបានបោះដាក់ស្លែងសរុបចំនួន............................. សន្លឹក
  + សន្លឹកឆ្នោតបានការចំនួន........................................................ សន្លឹក
  + សន្លឹកឆ្នោតមិនបានការចំនួន..................................................... សន្លឹក។
- **ការប្រកាសលទ្ធផលអ្នកជាប់ឆ្នោត៖** ក្រោយពីពិនិត្យលទ្ធផលនៃការបោះឆ្នោត ប្រធានអង្គប្រជុំត្រូវធ្វើការប្រកាសឈ្មោះបេក្ខជន ដែលបានជាប់ឆ្នោតជាប្រធាន ឬអនុប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត ស្របតាមគោលការណ៍ដែលបានកំណត់ក្នុងចំណុច២.៤(ខ.២.១)
- លទ្ធផលនៃការបោះឆ្នោតនេះ ត្រូវកត់ត្រានៅក្នុងកំណត់ហេតុត្រឹមត្រូវ និងច្បាស់លាស់។

## ៣. ការប្រកាសទទួលស្គាល់ប្រធាន អនុប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត

បន្ទាប់ពីការប្រកាសលទ្ធផលបោះឆ្នោត អភិបាលរាជធានី ខេត្តសាមីត្រូវចាត់ចែងរៀបចំសំណើមកក្រសួងមហាផ្ទៃដើម្បីដាក់ចេញប្រកាសទទួលស្គាល់ប្រធាន អនុប្រធានការិយាល័យប្រជាពលរដ្ឋរាជធានីខេត្តដោយផ្អែកតាមលទ្ធផលនៃកិច្ចប្រជុំបោះឆ្នោតជ្រើសរើសប្រធាន អនុប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត។ សំណើនេះត្រូវចុះហត្ថលេខាដោយអភិបាលរាជធានី ខេត្ត ក្នុងរយៈពេលប្រាំពីរ (៧)ថ្ងៃនៃថ្ងៃធ្វើការបន្ទាប់ពីថ្ងៃប្រកាសលទ្ធផលបោះឆ្នោត និងត្រូវភ្ជាប់មកជាមួយនូវកំណត់ហេតុនៃកិច្ចប្រជុំរបស់គណៈកម្មាធិការបោះឆ្នោត ប្រវត្តិរូបសង្ខេបរបស់បេក្ខជន និងឯកសារផ្សេងៗទៀត ដែលពាក់ព័ន្ធនឹងដំណើរការរៀបចំគណៈកម្មាធិការបោះឆ្នោត និងដំណើរការជ្រើសរើសប្រធាន អនុប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត។

ក្រោយពីទទួលបានសំណើនេះ ក្រសួងមហាផ្ទៃត្រូវពិនិត្យលើដំណើរការរៀបចំជ្រើសរើសប្រធាន អនុប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត មុននឹងដាក់ចេញប្រកាសទទួលស្គាល់តាមសំណើ។ ក្នុងករណីរកឃើញថាគណៈកម្មាធិការបោះឆ្នោតពុំបានអនុវត្តត្រឹមត្រូវតាមនីតិវិធីដូចបានកំណត់ក្នុងសេចក្តីណែនាំនេះ ក្រសួងមហាផ្ទៃត្រូវធ្វើការណែនាំឱ្យរៀបចំបោះឆ្នោតជ្រើសរើសប្រធាន អនុប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្តឡើងវិញ។

ប្រសិនបើគណៈកម្មាធិកាបោះឆ្នោតបានអនុវត្តត្រឹមត្រូវតាមនីតិវិធី ដូចបានកំណត់ក្នុងសេចក្តីណែនាំនេះ ក្រសួងមហាផ្ទៃត្រូវដាក់ចេញប្រកាសទទួលស្គាល់ប្រធាន អនុប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត មិនឱ្យលើសពីរយៈពេលសាមសិប(៣០)ថ្ងៃនៃថ្ងៃធ្វើការ ដោយគិតចាប់ពីថ្ងៃទទួលបានសំណើពីអភិបាលរាជធានី ខេត្ត។

## ៤. ការបាត់បង់មុខតំណែងប្រធាន អនុប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត

យោងមាត្រា១៣នៃអនុក្រឹត្យលេខ ១៩អនក្រ.បក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការបង្កើតការិយាល័យប្រជាពលរដ្ឋនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ប្រធាន អនុប្រធានការិយាល័យប្រជាពលរដ្ឋនឹងត្រូវបាត់បង់មុខតំណែងក្នុងករណីណាមួយដូចខាងក្រោម៖

- សាមីខ្លួនទទួលមរណភាព
- សាមីខ្លួនត្រូវតុលាការផ្តន្ទាទោសពីបទមជ្ឈិម ឬឧក្រិដ្ឋណាមួយ
- សាមីខ្លួនបាត់បង់សម្បទាវិជ្ជាជីវៈ
- សាមីខ្លួនសុំលាឈប់ដោយធ្វើលិខិតជាលាយលក្ខណ៍អក្សរ
- សាមីខ្លួនបោះបង់ចោលការងារ
- សាមីខ្លួនត្រូវគណៈកម្មាធិការបោះឆ្នោតជ្រើសរើសប្រធាន អនុប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្តសម្រេចដកចេញពីមុខតំណែង។

ដើម្បីធានាដល់និរន្តរភាពការងាររបស់ការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត ប្រធានគណៈកម្មាធិការបោះឆ្នោតត្រូវអនុវត្តតាមនីតិវិធីដូចខាងក្រោម៖

- **ករណីប្រធាន ឬអនុប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្តទទួលមរណភាព៖** ប្រធានគណៈកម្មាធិការបោះឆ្នោតត្រូវកោះប្រជុំគណៈកម្មាធិការបោះឆ្នោតក្នុងរយៈពេលមិនឱ្យលើសពីដប់ប្រាំ(១៥)ថ្ងៃនៃថ្ងៃធ្វើការគិតពីថ្ងៃទទួលមរណភាព ដើម្បីរៀបចំកំណត់ពេលវេលាធ្វើការប្រកាសជូនដំណឹងស្តីពីការបោះឆ្នោតជ្រើសរើសប្រធាន ឬអនុប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្តឡើងវិញជំនួសអ្នកដែលទទួលមរណភាព តាមនីតិវិធី និងជំហាននានា ដូចបានកំណត់ក្នុងចំណុច២នៃសេចក្តីណែនាំនេះ
- **ករណីប្រធាន ឬអនុប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្តត្រូវតុលាការផ្តន្ទាទោសពីបទមជ្ឈិម ឬឧក្រិដ្ឋណាមួយ៖** ប្រធានគណៈកម្មាធិការបោះឆ្នោតត្រូវកោះប្រជុំគណៈកម្មាធិការបោះឆ្នោតក្នុងរយៈពេលមិនឱ្យលើសពីប្រាំពីរ(០៧)ថ្ងៃនៃថ្ងៃធ្វើការគិតពីថ្ងៃទទួលបានសាលក្រមស្ថាពរ ឬសាលដីកាស្ថាពរ ដើម្បីរៀបចំកំណត់ពេលវេលាធ្វើការប្រកាសជូនដំណឹងស្តីពីការបោះឆ្នោតជ្រើសរើសប្រធាន ឬអនុប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្តឡើងវិញតាមនីតិវិធី និងជំហាននានា ដូចបានកំណត់ក្នុងចំណុច២នៃសេចក្តីណែនាំនេះ
- **ករណីប្រធាន ឬអនុប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្តបាត់បង់សម្បទាវិជ្ជាជីវៈ៖** ប្រធានគណៈកម្មាធិការបោះឆ្នោត ត្រូវកោះប្រជុំគណៈកម្មាធិការបោះឆ្នោតក្នុងរយៈពេលមិនឱ្យលើសពីប្រាំពីរ(០៧)ថ្ងៃនៃថ្ងៃធ្វើការគិតពីថ្ងៃទទួលបានលិខិតបញ្ជាក់ពីការបាត់បង់សម្បទាវិជ្ជាជីវៈពីក្រសួង ស្ថាប័នមានសមត្ថកិច្ច ដើម្បីរៀបចំកំណត់ពេលវេលាធ្វើការប្រកាសជូនដំណឹងស្តីពីការបោះឆ្នោតជ្រើសរើសប្រធាន ឬអនុប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្តឡើងវិញតាមនីតិវិធី និងជំហាននានា ដូចបានកំណត់ក្នុងចំណុច២នៃសេចក្តីណែនាំនេះ
- **ករណីប្រធាន ឬអនុប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្តសុំលាឈប់៖** ប្រធាន ឬអនុប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត ដែលមានបំណងសុំលាឈប់ពីការងារត្រូវធ្វើលិខិតជាលាយលក្ខណ៍អក្សរដាក់ជូនប្រធានគណៈកម្មាធិការបោះឆ្នោតឱ្យបានយ៉ាងតិចសាមសិប(៣០)ថ្ងៃមុនថ្ងៃលាឈប់ពីការងារ។ ប្រធានគណៈកម្មាធិការបោះឆ្នោតត្រូវកោះប្រជុំក្នុងរយៈពេលមិនឱ្យលើសពីប្រាំពីរ(០៧)ថ្ងៃនៃថ្ងៃធ្វើការ គិតពីថ្ងៃទទួលបានលិខិតស្នើសុំលាឈប់ពីសាមីខ្លួន ដើម្បីរៀបចំកំណត់ពេលវេលាធ្វើការប្រកាសជូនដំណឹងស្តីពីការបោះឆ្នោតជ្រើសរើសប្រធាន ឬអនុប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្តឡើងវិញ តាមនីតិវិធី និងជំហាននានា ដូចបានកំណត់ក្នុងចំណុច២នៃសេចក្តីណែនាំនេះ
- **ករណីប្រធាន ឬអនុប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្តបោះបង់ចោលការងារ៖** ប្រធាន ឬអនុប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្តដែលបានអវត្តមានគ្មានច្បាប់អនុញ្ញាតជាប់ៗគ្នាចាប់ពីដប់ប្រាំ(១៥)ថ្ងៃនៃថ្ងៃធ្វើការឡើងទៅ ត្រូវចាត់ទុកថាសាមីខ្លួនបានបោះបង់ចោលការងារ។ ក្នុងករណីនេះ ប្រធានគណៈកម្មាធិការបោះឆ្នោតត្រូវកោះប្រជុំគណៈកម្មាធិការបោះឆ្នោតក្នុងរយៈពេលមិនឱ្យលើសពីសាមសិប(៣០)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃដែលសាមីខ្លួនបានអវត្តមានដោយគ្មានច្បាប់អនុញ្ញាត ដើម្បីរៀបចំកំណត់ពេលវេលាធ្វើការប្រកាសជូនដំណឹងស្តីពីការបោះឆ្នោតជ្រើសរើសប្រធាន ឬអនុប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្តឡើងវិញតាមនីតិវិធី និងជំហាននានា ដូចបានកំណត់ក្នុងចំណុច២នៃសេចក្តីណែនាំនេះ

- **ករណីប្រធាន ឬអនុប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្តត្រូវគណៈកម្មាធិការបោះឆ្នោតសម្រេចដកចេញពីមុខតំណែង៖** សមាជិក១ភាគ៣នៃក្រុមប្រឹក្សារាជធានី ខេត្ត ឬសមាជិក១ភាគ៣នៃគណៈកម្មាធិការបោះឆ្នោតអាចដាក់សំណើជាលាយលក្ខណ៍អក្សរសុំដកប្រធាន ឬអនុប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្តចេញពីមុខតំណែងដោយមានបញ្ជាក់អំពីមូលហេតុច្បាស់លាស់ពាក់ព័ន្ធនឹងកំហុសឆ្គងក្នុងការងាររបស់ប្រធាន ឬអនុប្រធានការិយាល័យប្រជាពលរដ្ឋ។ បន្ទាប់ពីទទួលបានសំណើ ប្រធានគណៈកម្មាធិការបោះឆ្នោតអាចចាត់តាំងក្រុមការងារធ្វើការសិក្សាស្រាវជ្រាវបន្ថែមមុននឹងកោះប្រជុំគណៈកម្មាធិការបោះឆ្នោត។ ក្នុងករណីការសិក្សាស្រាវជ្រាវរកឃើញថាសំណើនេះពុំមានមូលហេតុសមស្រប ប្រធានគណៈកម្មាធិការមិនត្រូវកោះប្រជុំដើម្បីអនុម័តលើសំណើសុំដកមុខតំណែងប្រធាន ឬអនុប្រធានការិយាល័យប្រជាពលរដ្ឋទេ ហើយត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដោយភ្ជាប់ជាមួយរបាយការណ៍សិក្សាស្រាវជ្រាវទៅសមាជិកទាំងអស់នៃគណៈកម្មាធិការបោះឆ្នោត។ ក្នុងករណីការសិក្សាស្រាវជ្រាវរកឃើញថាសំណើនេះមានមូលហេតុសមស្រប ប្រធានគណៈកម្មាធិការត្រូវកោះប្រជុំគណៈកម្មាធិការបោះឆ្នោតរបស់ខ្លួន។ កិច្ចប្រជុំរបស់គណៈកម្មាធិការបោះឆ្នោតអាចដំណើរការដើម្បីពិនិត្យ សម្រេចលើសំណើសុំដកចេញពីមុខតំណែងប្រធាន ឬអនុប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត ត្រូវមានកូរ៉ុមលើសពីពាក់កណ្ដាលនៃសមាជិកគណៈកម្មាធិការបោះឆ្នោត។ ការអនុម័តដកចេញពីមុខតំណែងប្រធាន ឬអនុប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត ត្រូវមានសំឡេងគាំទ្រលើសពីពាក់កណ្ដាលនៃសមាជិកគណៈកម្មាធិការបោះឆ្នោតទាំងអស់។ ក្នុងករណីគណៈកម្មាធិការបោះឆ្នោតបានអនុម័តគាំទ្រលើសំណើសុំដកចេញពីមុខតំណែងប្រធាន ឬអនុប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត អភិបាលរាជធានី ខេត្តសាមីត្រូវចាត់ចែងរៀបចំសំណើមកក្រសួងមហាផ្ទៃ ដើម្បីដាក់ចេញប្រកាសបញ្ចប់មុខតំណែងប្រធាន ឬអនុប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត ដោយផ្អែកតាមលទ្ធផលនៃកិច្ចប្រជុំរបស់គណៈកម្មាធិការបោះឆ្នោត។ សំណើនេះត្រូវចុះហត្ថលេខាដោយអភិបាលរាជធានី ខេត្ត ក្នុងរយៈពេលប្រាំពីរ(៧)ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីថ្ងៃប្រជុំអនុម័តដកចេញពីមុខតំណែងប្រធាន ឬអនុប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត ដោយភ្ជាប់មកជាមួយនូវកំណត់ហេតុកិច្ចប្រជុំ និងឯកសារពាក់ព័ន្ធផ្សេងៗទៀត។ ក្រោយពីទទួលបានសំណើនេះក្រសួងមហាផ្ទៃត្រូវពិនិត្យអំពីនីតិវិធីនៃការដកចេញពីមុខតំណែងប្រធាន ឬអនុប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត មុននឹងដាក់ចេញប្រកាសបញ្ចប់មុខតំណែងប្រធាន ឬអនុប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត។ ក្នុងករណីសំណើសុំដកចេញពីមុខតំណែងមិនមានមូលហេតុសមស្រប ឬការអនុវត្តនីតិវិធីនៃការដកចេញពីមុខតំណែងមិនត្រឹមត្រូវ ក្រសួងមហាផ្ទៃត្រូវធ្វើការណែនាំដល់គណៈកម្មាធិការបោះឆ្នោតដើម្បីចាត់វិធានការអនុវត្ត ឬកែតម្រូវតាមករណីជាក់ស្ដែងនីមួយៗ។ គណៈកម្មាធិការបោះឆ្នោតអាចរៀបចំដំណើរការជ្រើសរើសប្រធាន ឬអនុប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត ជំនួសប្រធាន ឬអនុប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត ដែលបានដកចេញពីមុខតំណែងក្រោយពីទទួលបានប្រកាសបញ្ចប់មុខតំណែងពីក្រសួងមហាផ្ទៃ។

ប្រធាន ឬអនុប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត ដែលបានជាប់ឆ្នោតជំនួសមុខតំណែងដែលបានបាត់បង់តាមករណីខាងលើនេះ ត្រូវមានអាណត្តិការងាររយៈពេលប្រាំ( ៥ )ឆ្នាំគិតពីថ្ងៃក្រសួងមហាផ្ទៃចេញប្រកាសទទួលស្គាល់។

ចំពោះការជ្រើសរើសប្រធាន អនុប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្តថ្មីជំនួសប្រធាន អនុប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្តដែលត្រូវចប់អាណត្តិការងារ គណៈកម្មាធិការបោះឆ្នោតត្រូវរៀបចំការបោះឆ្នោតជ្រើសរើសប្រធាន អនុប្រធានការិយាល័យប្រជាពលរដ្ឋឱ្យបានយ៉ាងតិច២ខែមុនថ្ងៃចប់អាណត្តិការងារ។

ទទួលបានសេចក្តីណែនាំនេះ គ្រប់អង្គភាពពាក់ព័ន្ធចំណុះក្រសួងមហាផ្ទៃ និងគ្រប់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវអនុវត្តឱ្យមានប្រសិទ្ធភាព និងដោយស្មារតីទទួលខុសត្រូវខ្ពស់។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ សីហា ឆ្នាំ២០១៧

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

**កន្លែងទទួល ៖**

- *ទីស្តីការគណៈរដ្ឋមន្ត្រី*
- *ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*
- *ក្រសួង ស្ថាប័នពាក់ព័ន្ធ*
- *អង្គភាពប្រឆាំងអំពើពុករលួយ*
- *លេខាធិការដ្ឋាន គ.ជ.អ.ប*
- *អគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ*
- *ខុទ្ទកាល័យសម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ*
- *រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ*
- *សភាពាណិជ្ជកម្មកម្ពុជា*
- *ឯកសារ កាលប្បវត្តិ*

# បញ្ជីឈ្មោះបេក្ខជន
## តំណាងអង្គការសង្គមស៊ីវិល

| ល.រ | ឈ្មោះបេក្ខជន | ភេទ | ថ្ងៃខែឆ្នាំកំណើត | អង្គការសង្គមស៊ីវិល |
|---|---|---|---|---|
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |

# គំរូសន្លឹកឆ្នោត

សូមលោក លោកស្រីបោះឆ្នោតជ្រើសរើសតំណាងអង្គការសង្គមស៊ីវិលចំនួន...........រូប
ដោយសរសេរលេខរៀងបេក្ខជន ឬឈ្មោះបេក្ខជន ឬឈ្មោះអង្គការសង្គមស៊ីវិល
ដែលខ្លួនពេញចិត្ត

- ............................................................................................................................................
- ............................................................................................................................................
- ............................................................................................................................................
- ............................................................................................................................................
- ............................................................................................................................................
- ............................................................................................................................................
- ............................................................................................................................................

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋបាលរាជធានី ខេត្ត................

គណៈកម្មាធិការបោះឆ្នោតជ្រើសរើស

ប្រធាន អនុប្រធានការិយាល័យប្រជាពលរដ្ឋ

# សេចក្តីជូនដំណឹង

## ស្តីពី

## ការជ្រើសរើសប្រធាន អនុប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី/ខេត្ត.......................

រដ្ឋបាលរាជធានី/ខេត្ត............មានកិត្តិយសសូមជូនដំណឹងដល់ប្រជាពលរដ្ឋ និងសាធារណជនទាំងអស់ឱ្យបានជ្រាបថា រដ្ឋបាលរាជធានី/ខេត្ត...........................................នឹងធ្វើការជ្រើសរើសប្រធាន អនុប្រធានការិយាល័យប្រជាពលរដ្ឋចំនួន២រូប ដើម្បីបំពេញការងារនៅការិយាល័យប្រជាពលរដ្ឋរាជធានី/ខេត្ត..........................................។

ការិយាល័យប្រជាពលរដ្ឋរាជធានី/ខេត្ត.......................មានតួនាទីទទួល និងសម្រុះសម្រួលដោះស្រាយបណ្តឹងក្រៅប្រព័ន្ធតុលាការ ដែលពាក់ព័ន្ធនឹងការផ្តល់សេវាសាធារណៈ និងការគ្រប់គ្រងរដ្ឋបាលនៅថ្នាក់ក្រោមជាតិ ក្នុងគោលបំណងលើកកម្ពស់អភិបាលកិច្ចល្អក្នុងការផ្តល់សេវា និងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋានប្រកបដោយតម្លាភាព គណនេយ្យភាព និងប្រសិទ្ធភាពសំដៅបង្កើនជំនឿទុកចិត្តរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន។

ប្រធាន អនុប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី/ខេត្ត................នឹងត្រូវជ្រើសរើសតាមរយៈការបោះឆ្នោតដោយគណៈកម្មាធិការបោះឆ្នោតមួយ ដែលមានសមាសភាពមកពីក្រុមប្រឹក្សារាជធានី ខេត្ត សមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ តំណាងសភាពាណិជ្ជកម្មរាជធានី ខេត្ត និងតំណាងអង្គការសង្គមស៊ីវិល។

**១. មុខតំណែងដែលត្រូវជ្រើសរើស**

- ប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត ១រូប
- អនុប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត ១រូប

**២. លក្ខខណ្ឌ និងលក្ខណសម្បត្តិ**

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានបំណងដាក់ពាក្យឈរឈ្មោះជាបេក្ខជនប្រធាន អនុប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត ត្រូវមានលក្ខខណ្ឌ និងលក្ខណសម្បត្តិដូចខាងក្រោម៖

- មានសញ្ជាតិខ្មែរពីកំណើត
- មានអាយុចាប់ពី៣៥ឆ្នាំទៅ៦៥ឆ្នាំ គិតដល់ថ្ងៃបោះឆ្នោត
- សញ្ញាបត្រចាប់ពីបរិញ្ញាបត្រ ឬសញ្ញាបត្រសមមូលពាក់ព័ន្ធនឹងផ្នែកច្បាប់ ឬរដ្ឋបាល ឬផ្នែកដទៃទៀតពាក់ព័ន្ធនឹងការដោះស្រាយទំនាស់

- មានបទពិសោធក្នុងការងារពាក់ព័ន្ធនឹងផ្នែកច្បាប់ ឬរដ្ឋបាល ឬផ្នែកដទៃទៀតពាក់ព័ន្ធនឹងការដោះស្រាយទំនាស់យ៉ាងតិច៣ឆ្នាំ
- ជាបុគ្គលស្អាតស្អំ មានកេរ្តិ៍ឈ្មោះល្អ មានការគោរពរាប់អានពីសហគមន៍របស់ខ្លួន
- មានទីលំនៅអចិន្ត្រៃយ៍នៅក្នុងរាជធានី ខេត្ត ដែលសាមីជនមានបំណងឈរឈ្មោះ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលគ្មានសិទ្ធិឈរឈ្មោះជាបេក្ខជនប្រធាន អនុប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្តៈ

- មន្ត្រីរាជការស៊ីវិល មន្ត្រីតុលាការ កងយោធពលខេមរភូមិន្ទ ឬនគរបាលជាតិ
- សមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់
- ព្រះសង្ឃ ឬបុព្វជិតសាសនា
- ជនដែលត្រូវបានផ្តន្ទាទោសពីបទមជ្ឈិម ឬឧក្រិដ្ឋ ហើយមិនមាននីតិសម្បទាឡើងវិញ
- ជនដែលស្ថិតនៅក្នុងរចនាសម្ព័ន្ធចាត់តាំងរបស់គណបក្សនយោបាយណាមួយ។

### ៣. តួនាទី ភារកិច្ច

តួនាទី ភារកិច្ចនៃមុខតំណែងប្រធាន អនុប្រធានការិយាល័យប្រជាពលរដ្ឋ មានកំណត់នៅក្នុងលក្ខខណ្ឌការងារដែលមានភ្ជាប់ជាមួយនឹងសេចក្តីជូនដំណឹង និងពាក្យស្នើសុំ។

### ៤. សំណុំឯកសារសម្រាប់ដាក់ពាក្យ

| | | |
|---|---|---|
| - | ពាក្យស្នើសុំ | ១ ច្បាប់ |
| - | ប្រវត្តិរូបសង្ខេបមានបិទរូបថត៤x៦ | ១ ច្បាប់ |
| - | សេចក្តីចម្លងសំបុត្រកំណើត ឬបញ្ជាក់កំណើត | ១ ច្បាប់ |
| - | សៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅ ដែលថតចម្លងតាមច្បាប់ដើម | ១ ច្បាប់ |
| - | សញ្ញាបត្រ និងឬវិញ្ញាបនបត្រនានា ដែលថតចម្លងតាមច្បាប់ដើម | ១ ច្បាប់ |
| - | រូបថត៤x៦ | ២ សន្លឹក |

### ៥. ទីកន្លែងទទួលពាក្យ និងកាលបរិច្ឆេទឈប់ទទួលពាក្យ

បេក្ខជនដែលមានបំណងចង់ឈរឈ្មោះជាប្រធាន អនុប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្តត្រូវមកទទួលពាក្យ និងដាក់ពាក្យស្នើសុំនៅការិយាល័យលេខាធិការក្រុមប្រឹក្សារាជធានី ខេត្ត រៀងរាល់ម៉ោងធ្វើការចាប់ពីថ្ងៃជូនដំណឹងនេះតទៅ។

កាលបរិច្ឆេទឈប់ទទួលពាក្យស្នើសុំត្រឹមថ្ងៃទី.......ខែ......ឆ្នាំ..........វេលាម៉ោង០៥:០០រសៀល។

ការចែកពាក្យស្នើសុំនិងលក្ខខណ្ឌការងារ ការដាក់និងការទទួលពាក្យស្នើសុំពុំតម្រូវឱ្យមានការបង់ប្រាក់ឡើយ។

### ៦. ប្រាក់ឧបត្ថម្ភ និងអត្ថប្រយោជន៍

ប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត មានប្រាក់ឧបត្ថម្ភប្រចាំខែចំនួន ...................រៀល។

អនុប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត មានប្រាក់ឧបត្ថម្ភប្រចាំខែចំនួន ............រៀល។

ប្រធាន អនុប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្តអាចទទួលបានអត្ថប្រយោជន៍ផ្សេងៗទៀត តាមការកំណត់របស់រដ្ឋបាលរាជធានី ខេត្ត។

បេក្ខជនជាស្ត្រី ជនពិការ និងជនជាតិដើមភាគតិច ត្រូវបានផ្តល់អាទិភាពនិងលើកទឹកចិត្តឱ្យដាក់ពាក្យឈរឈ្មោះជាបេក្ខជនសម្រាប់មុខតំណែងខាងលើនេះ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមប្រជាពលរដ្ឋ និងសាធារណជនទាំងអស់ដែលមានលក្ខណសម្បត្តិសមស្របដូចបានកំណត់នៅក្នុងសេចក្តីជូនដំណឹងនេះ និងមានបំណងឈរឈ្មោះជាបេក្ខជនសម្រាប់មុខតំណែងខាងលើ អញ្ជើញមកទទួល និងដាក់ពាក្យស្នើសុំនៅទីកន្លែង និងតាមកាលបរិច្ឆេទដូចបានកំណត់ខាងលើ។

ទំនាក់ទំនងសាកសួរព័ត៌មានបន្ថែម៖ លោក/លោកស្រី.................... លេខទូរស័ព្ទ................។

ធ្វើនៅ................ ថ្ងៃទី.......ខែ...........ឆ្នាំ.........

**អភិបាល**

**<u>ចម្លងជូន</u>** ÷

*- ក្រសួងមហាផ្ទៃ*

"ដើម្បីជូនជ្រាប"

*- មន្ទីរ អង្គភាពពាក់ព័ន្ធរាជធានី/ខេត្ត........*

*- រដ្ឋបាលក្រុង/ស្រុក/ខណ្ឌ.........*

"ដើម្បីផ្សព្វផ្សាយ"

*-ឯកសារ កាលប្បវត្តិ*

ទម្រង់គំរូទី៤-ក៖ លក្ខខណ្ឌការងារ(ប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត)

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលរាជធានី ខេត្ត...............**

**គណៈកម្មាធិការបោះឆ្នោតជ្រើសរើស**

**ប្រធាន អនុប្រធានការិយាល័យប្រជាពលរដ្ឋ**

**លក្ខខណ្ឌការងារ**

| | |
|---|---|
| **មុខតំណែង** | ប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត |
| **ទីកន្លែងបំពេញការងារ** | ការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត |
| **ស្ថិតនៅក្រោមការគ្រប់គ្រង** | ប្រធានក្រុមប្រឹក្សារាជធានី ខេត្ត |

## ១. ប្រវត្តិ

រាជរដ្ឋាភិបាលបានដាក់ចេញច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ដើម្បីផ្តល់នូវក្របខ័ណ្ឌគតិយុត្តសម្រាប់ការរៀបចំ និងការប្រព្រឹត្តទៅនៃរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ តាមគោលការណ៍នៃរដ្ឋបាលឯកភាព ដើម្បីបង្កើត ជំរុញ និងធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ។ ក្រុមប្រឹក្សានីមួយៗនៅរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានបង្កើតឡើងតាមរយៈការបោះឆ្នោតអសកល ហើយបាននិងកំពុងបំពេញការងាររបស់ខ្លួនទៅតាមអាណត្តិ និងតួនាទី ភារកិច្ចដែលបានកំណត់នៅក្នុងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

ក្នុងគោលបំណងលើកកម្ពស់អភិបាលកិច្ចល្អក្នុងការផ្តល់សេវា និងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន រាជរដ្ឋាភិបាលបានដាក់ចេញនូវអនុក្រឹត្យលេខ១៩ អនក្រ.បក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការបង្កើតការិយាល័យប្រជាពលរដ្ឋនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលជាយន្តការអព្យាក្រឹតមួយសម្រាប់ទទួល និងសម្រុះសម្រួលដោះស្រាយបណ្តឹងក្រៅប្រព័ន្ធតុលាការ ដែលពាក់ព័ន្ធនឹងការផ្តល់សេវាសាធារណៈ និងការគ្រប់គ្រងរដ្ឋបាលនៅថ្នាក់ក្រោមជាតិ។ ការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្តដឹកនាំដោយប្រធាន ១រូប និងមានអនុប្រធាន១រូបជាជំនួយការ។ ប្រធាន អនុប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត ត្រូវជ្រើសរើសឡើងតាមការបោះឆ្នោតដោយគណៈកម្មាធិការបោះឆ្នោត ដែលមានសមាសភាពមកពីក្រុមប្រឹក្សារាជធានី ខេត្ត សមាគមក្រុមប្រឹក្សាក្រុង ស្រុក ឃុំ សង្កាត់ តំណាងសភាពាណិជ្ជកម្មរាជធានី ខេត្ត និងតំណាងអង្គការសង្គមស៊ីវិល។

## ២. ភារកិច្ច និងការទទួលខុសត្រូវ

មុខតំណែងប្រធានការិយាល័យប្រជាពលរដ្ឋ មានភារកិច្ចដូចខាងក្រោម៖

- គ្រប់គ្រង ដឹកនាំ សម្របសម្រួលការងារប្រចាំថ្ងៃរបស់ការិយាល័យប្រជាពលរដ្ឋ

- ចាត់ចែង រៀបចំឱ្យមានបុគ្គលិកបំពេញការងារស្របតាមរចនាសម្ព័ន្ធ និងតួនាទី ភារកិច្ចរបស់ការិយាល័យប្រជាពលរដ្ឋ
- កំណត់លក្ខខណ្ឌការងារ និងក្រមសីលធម៌ឱ្យបានច្បាស់លាស់សម្រាប់បុគ្គលិកបំពេញការងារនៅការិយាល័យប្រជាពលរដ្ឋ
- ចាត់ចែងប្រមូល និងទទួលពាក្យបណ្ដឹងនានានៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ដឹកនាំដំណើរការពិនិត្យ សម្រាំង និងវាយតម្លៃពាក្យបណ្ដឹងដែលទទួលបាន
- តាមដានដំណើរការបញ្ជូនពាក្យបណ្ដឹង ដែលមិនស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួនទៅស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធនិងតាមដានការដោះស្រាយ ដើម្បីជូនព័ត៌មានទៅម្ចាស់ពាក្យបណ្ដឹង
- ដឹកនាំការស៊ើបអង្កេត លើកអនុសាសន៍លើវិធានការដោះស្រាយបណ្ដឹង និងតាមដានការអនុវត្តវិធានការដោះស្រាយបណ្ដឹងដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ផ្ដល់ព័ត៌មានគ្រឡប់ដល់ប្រជាពលរដ្ឋអំពីលទ្ធផលដោះស្រាយបណ្ដឹង
- រៀបចំផែនការ និងសហការផ្សព្វផ្សាយឱ្យបានទូលំទូលាយអំពីយន្តការសម្រុះសម្រួលដោះស្រាយបណ្ដឹងរដ្ឋបាលដល់ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធ
- រៀបចំយន្តការចាំបាច់នានាពាក់ព័ន្ធទៅនឹងដំណើរការទទួលនិងសម្រុះសម្រួលដោះស្រាយបណ្ដឹងរដ្ឋបាលនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ចាត់តាំងតំណាងរបស់ខ្លួនទៅបំពេញការងារនៅអង្គភាពច្រកចេញចូលតែមួយ តាមគោលការណ៍កំណត់
- រៀបចំ និងអនុវត្តផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំរបស់ការិយាល័យប្រជាពលរដ្ឋ
- រៀបចំរបាយការណ៍អំពីលទ្ធផលនៃការអនុវត្តការងារនិងការដោះស្រាយបណ្ដឹងរបស់ការិយាល័យប្រជាពលរដ្ឋតាមគោលការណ៍កំណត់
- រាយការណ៍អំពីលទ្ធផលការងាររបស់ការិយាល័យប្រជាពលរដ្ឋជូនកិច្ចប្រជុំក្រុមប្រឹក្សា។

**៣. របាយការណ៍**

ប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្តត្រូវរៀបចំរបាយការណ៍ជូនប្រធានក្រុមប្រឹក្សារាជធានី ខេត្តសាមី និងចម្លងជូនក្រសួងមហាផ្ទៃតាមការកំណត់។

ទម្រង់គំរូទី៤-ខ៖ លក្ខខណ្ឌការងារ (អនុប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត)

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលរាជធានី ខេត្ត................**

**គណៈកម្មាធិការបោះឆ្នោតជ្រើសរើស**

**ប្រធាន អនុប្រធានការិយាល័យប្រជាពលរដ្ឋ**

**លក្ខខណ្ឌការងារ**

| | |
|---|---|
| **មុខតំណែង** | អនុប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត |
| **ទីកន្លែងបំពេញការងារ** | ការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត |
| **ស្ថិតនៅក្រោមការគ្រប់គ្រង** | ប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត |

## ១. ប្រវត្តិ

រាជរដ្ឋាភិបាលបានដាក់ចេញច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និង ច្បាប់ស្ដីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ដើម្បីផ្ដល់នូវក្របខ័ណ្ឌគតិយុត្តសម្រាប់ការរៀបចំ និងការប្រព្រឹត្តទៅនៃរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ តាមគោលការណ៍នៃរដ្ឋបាលឯកភាព ដើម្បីបង្កើត ជំរុញ និងធ្វើឱ្យមាន ចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ។ ក្រុមប្រឹក្សានីមួយៗនៅរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបាន បង្កើតឡើងតាមរយៈការបោះឆ្នោតអសកល ហើយ បាននិងកំពុងបំពេញការងាររបស់ខ្លួនទៅតាមអាណត្តិ និងតួនាទី ភារកិច្ចដែលបានកំណត់នៅក្នុងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

ក្នុងគោលបំណងលើកកម្ពស់អភិបាលកិច្ចល្អក្នុងការផ្ដល់សេវា និងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន រាជរដ្ឋាភិបាលបានដាក់ចេញនូវអនុក្រឹត្យលេខ១៩ អនក្រ.បក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧ ស្ដីពីការ បង្កើតការិយាល័យប្រជាពលរដ្ឋនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលជាយន្តការអព្យាក្រឹតមួយសម្រាប់ទទួល និងសម្រុះសម្រួលដោះស្រាយបណ្ដឹងក្រៅប្រព័ន្ធតុលាការ ដែលពាក់ព័ន្ធនឹងការផ្ដល់សេវាសាធារណៈ និងការគ្រប់គ្រងរដ្ឋបាលនៅថ្នាក់ក្រោមជាតិ។ ការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្តដឹកនាំដោយប្រធាន ១រូប និងមានអនុប្រធាន១រូបជាជំនួយការ។ ប្រធាន អនុប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត ត្រូវជ្រើសរើសឡើងតាមការបោះឆ្នោតដោយគណៈកម្មាធិការបោះឆ្នោត ដែលមានសមាសភាពមកពីក្រុម ប្រឹក្សារាជធានី ខេត្ត សមាគមក្រុមប្រឹក្សាក្រុង ស្រុក ឃុំ សង្កាត់ តំណាងសភាពាណិជ្ជកម្មរាជធានី ខេត្ត និងតំណាងអង្គការសង្គមស៊ីវិល។

## ២. ភារកិច្ច និងការទទួលខុសត្រូវ

មុខតំណែងអនុប្រធានការិយាល័យប្រជាពលរដ្ឋ មានភារកិច្ចដូចខាងក្រោម៖

- ជួយប្រធានលើការដឹកនាំការងារប្រចាំថ្ងៃរបស់ការិយាល័យប្រជាពលរដ្ឋ
- ចូលរួមសម្របសម្រួលក្នុងការប្រមូលនិងទទួលពាក្យបណ្ដឹងនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន

- ចូលរួមក្នុងដំណើរការពិនិត្យ សម្រាំង និងវាយតម្លៃពាក្យបណ្តឹងដែលទទួលបាន
- ជួយប្រធានក្នុងការតាមដានដំណើរការបញ្ជូនពាក្យបណ្តឹង ដែលមិនស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួនទៅស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធនិងតាមដានការដោះស្រាយ ដើម្បីជូនព័ត៌មានទៅម្ចាស់ពាក្យបណ្តឹង
- ជួយដឹកនាំការស៊ើបអង្កេត លើកអនុសាសន៍លើវិធានការដោះស្រាយបណ្តឹង និងតាមដានការអនុវត្តវិធានការដោះស្រាយបណ្តឹងដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ចូលរួមរៀបចំផែនការ និងសម្របសម្រួលជាមួយអង្គភាព ស្ថាប័នពាក់ព័ន្ធដើម្បីផ្សព្វផ្សាយឱ្យបានទូលំទូលាយអំពីយន្តការសម្រុះសម្រួលដោះស្រាយបណ្តឹងរដ្ឋបាលដល់ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធ
- ចូលរួមរៀបចំយន្តការចាំបាច់នានាពាក់ព័ន្ធទៅនឹងដំណើរការទទួលនិងសម្រុះសម្រួលដោះស្រាយបណ្តឹងរដ្ឋបាលនៅក្នុងដែនសមត្ថកិច្ចរបស់ការិយាល័យប្រជាពលរដ្ឋ
- ចូលរួមរៀបចំ និងអនុវត្តផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំរបស់ការិយាល័យប្រជាពលរដ្ឋ
- ជួយរៀបចំរបាយការណ៍អំពីលទ្ធផលនៃការអនុវត្តការងារ និងការដោះស្រាយបណ្តឹងរបស់ការិយាល័យប្រជាពលរដ្ឋតាមគោលការណ៍កំណត់
- ទទួលភារកិច្ចជាប្រធានការិយាល័យប្រជាពលរដ្ឋស្តីទីនៅពេលប្រធានអវត្តមានតាមការផ្ទេរសិទ្ធិ
- ទទួលភារកិច្ចផ្សេងទៀតតាមការចាត់តាំងរបស់ប្រធានការិយាល័យប្រជាពលរដ្ឋ។

**៣. របាយការណ៍**

អនុប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត ត្រូវរាយការណ៍ជាប្រចាំអំពីការអនុវត្តការងាររបស់ខ្លួនជូនប្រធានការិយាល័យប្រជាពលរដ្ឋ និងជួយរៀបចំរបាយការណ៍អំពីលទ្ធផលនៃការអនុវត្តការងាររបស់ការិយាល័យប្រជាពលរដ្ឋជូនប្រធានក្រុមប្រឹក្សារាជធានី ខេត្តសាមី។

ទម្រង់គំរូទី៥៖ ពាក្យស្នើសុំ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# ពាក្យស្នើសុំ

នាងខ្ញុំ/ខ្ញុំបាទឈ្មោះ...........................................អក្សរឡាតាំង...................................
ថ្ងៃខែឆ្នាំកំណើត៖...................................សញ្ជាតិ.......................ជនជាតិ...................................
ទីកន្លែងកំណើត៖ភូមិ...........................................ឃុំ/សង្កាត់...................................................
ក្រុង/ស្រុក/ខណ្ឌ..........................................រាជធានី/ខេត្ត........................................................
ទីលំនៅបច្ចុប្បន្ន៖ផ្ទះលេខ.........ផ្លូវលេខ...........ភូមិ......................ឃុំ/សង្កាត់...............................
ក្រុង/ស្រុក/ខណ្ឌ..........................រាជធានី/ខេត្ត.........................លេខទូរស័ព្ទ...........................។

**សូមគោរពជូន**

**ឯកឧត្តមប្រធានគណៈកម្មាធិការបោះឆ្នោតជ្រើសរើសប្រធាន អនុប្រធានការិយាល័យ**

**ប្រជាពលរដ្ឋរាជធានី/ខេត្ត**.......................................

**កម្មវត្ថុ៖** សំណើសុំដាក់ពាក្យឈរឈ្មោះជា...............................................ការិយាល័យប្រជាពលរដ្ឋ រាជធានី/ខេត្ត.....................................................។

សេចក្ដីដូចមានចែងនៅក្នុងកម្មវត្ថុខាងលើ នាងខ្ញុំ/ខ្ញុំបាទសូមគោរពជូនឯកឧត្តមប្រធានគណៈកម្មាធិការបោះឆ្នោតមេត្តាជ្រាបថា នាងខ្ញុំ/ខ្ញុំបាទមានបំណងឈរឈ្មោះជាបេក្ខជនសម្រាប់ការបោះឆ្នោតជ្រើសរើសមុខតំណែង.....................ការិយាល័យប្រជាពលរដ្ឋរាជធានី/ខេត្ត...............................។

អាស្រ័យហេតុនេះ សូមឯកឧត្តមប្រធានគណៈកម្មាធិការបោះឆ្នោតជ្រើសរើសប្រធាន អនុប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី/ខេត្ត.......................មេត្តាពិនិត្យលទ្ធភាព និងអនុញ្ញាតឱ្យនាងខ្ញុំ/ខ្ញុំបាទបានឈរឈ្មោះជាបេក្ខជនដោយសេចក្ដីអនុគ្រោះ។

សូមឯកឧត្តមប្រធានគណៈកម្មាធិការបោះឆ្នោតមេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីនាងខ្ញុំ/ខ្ញុំបាទ។

**សូមជូនភ្ជាប់មកជាមួយនូវ៖**

| | |
|---|---|
| ១. ប្រវត្តិរូបសង្ខេបមានបិទរូបថត៤x៦ | ១ ច្បាប់ |
| ២. សេចក្ដីចម្លងសំបុត្រកំណើត ឬបញ្ជាក់កំណើត | ១ ច្បាប់ |
| ៣.សៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅ ដែលថតចម្លងតាមច្បាប់ដើម | ១ ច្បាប់ |
| ៤. សញ្ញាបត្រ និងឬវិញ្ញាបនបត្រនានា ដែលថតចម្លងតាមច្បាប់ដើម | ១ ច្បាប់ |
| ៥. រូបថត៤x៦ | ២ សន្លឹក |

*ធ្វើនៅ..................ថ្ងៃទី.......ខែ.........ឆ្នាំ២០.....*

**ហត្ថលេខា និងឈ្មោះរបស់សាមីខ្លួន**

ទម្រង់គំរូទី៦៖ របាយការណ៍ស្តីពីការដាក់ពាក្យ និងការទទួលពាក្យស្នើសុំ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលរាជធានី ខេត្ត................**

**គណៈកម្មាធិការបោះឆ្នោតជ្រើសរើសប្រធាន**

**អនុប្រធានការិយាល័យប្រជាពលរដ្ឋ**

**សូមគោរពជូន**

**ឯកឧត្តមប្រធានគណៈកម្មាធិការបោះឆ្នោតជ្រើសរើសប្រធាន អនុប្រធានការិយាល័យ**

**ប្រជាពលរដ្ឋរាជធានី/ខេត្ត.......................................**

**កម្មវត្ថុ៖** របាយការណ៍ស្តីពីលទ្ធផលនៃការដាក់ពាក្យ និងការទទួលពាក្យស្នើសុំឈរឈ្មោះជាប្រធាន អនុប្រធានការិយាល័យប្រជាពលរដ្ឋ។

**យោង៖** សេចក្តីជូនដំណឹងចុះថ្ងៃទី.......ខែ.............ឆ្នាំ...........ស្តីពីការជ្រើសរើសប្រធាន អនុប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី/ខេត្ត...................................។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ នាងខ្ញុំ/ខ្ញុំបាទសូមគោរពជម្រាបជូនឯកឧត្តមប្រធានគណៈកម្មាធិការបោះឆ្នោតជ្រើសរើសប្រធាន អនុប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី/ខេត្តមេត្តាជ្រាបថា គណៈកម្មាធិការបោះឆ្នោតបានប្រកាសផ្សព្វផ្សាយ និងទទួលពាក្យស្នើសុំឈរឈ្មោះជាបេក្ខជនសម្រាប់មុខតំណែងប្រធាន អនុប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្តចាប់តាំងពីថ្ងៃទី.......ខែ.......ឆ្នាំ...........រហូតដល់ថ្ងៃទី.......ខែ.......ឆ្នាំ...........វេលាម៉ោង០៥:០០រសៀល។

ក្រោយពីថ្ងៃផុតកំណត់ទទួលពាក្យខាងលើនេះ ការិយាល័យលេខាធិការក្រុមប្រឹក្សារាជធានី ខេត្តបានទទួលពាក្យស្នើសុំឈរឈ្មោះជាបេក្ខជនសម្រាប់មុខតំណែងនីមួយៗដូចខាងក្រោម៖

| ល.រ | មុខតំណែង | សរុប | ស្រី |
|---|---|---|---|
| ១ | ប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត | | |
| ២ | អនុប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត | | |
| | សរុប | | |

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមប្រធានគណៈកម្មាធិការបោះឆ្នោត មេត្តាជ្រាបជារបាយការណ៍។

សូមឯកឧត្តមប្រធានមេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ។

សូមជូនភ្ជាប់មកជាមួយនូវបញ្ជីឈ្មោះបេក្ខជនដែលបានដាក់ពាក្យស្នើសុំចំនួន១ច្បាប់។

**ប្រធានការិយាល័យលេខាធិការក្រុមប្រឹក្សា**

ទម្រង់គំរូទី៧៖ បញ្ជីឈ្មោះបេក្ខជន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋបាលរាជធានី ខេត្ត..............

គណៈកម្មាធិការបោះឆ្នោតជ្រើសរើសប្រធាន

អនុប្រធានការិយាល័យប្រជាពលរដ្ឋ

## បញ្ជីឈ្មោះបេក្ខជនដែលបានដាក់ពាក្យស្នើសុំ
## សម្រាប់ឈរឈ្មោះបោះឆ្នោតជ្រើសរើសប្រធាន អនុប្រធានការិយាល័យប្រជាពលរដ្ឋ

| ល.រ | ឈ្មោះ | ភេទ | អាយុ | ទីលំនៅអចិន្ត្រៃយ៍ | សញ្ញាបត្រ | បទពិសោធន៍ការងារ |
|---|---|---|---|---|---|---|
| ក ).មុខតំណែងប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| ខ ).មុខតំណែងអនុប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |

................,ថ្ងៃទី.........ខែ.........ឆ្នាំ.......

**បានឃើញ និងឯកភាព**

**ប្រធានគណៈកម្មាធិការបោះឆ្នោត**

.........................,ថ្ងៃទី.........ខែ.........ឆ្នាំ.......

**ប្រធានការិយាល័យលេខាធិការក្រុមប្រឹក្សា**

ទម្រង់គំរូទី៨៖ បញ្ជីឈ្មោះសម្រាំងបេក្ខជន

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋធានីរាជធានី ខេត្ត.................**

**គណៈកម្មាធិការបោះឆ្នោតជ្រើសរើសប្រធាន**

**អនុប្រធានការិយាល័យប្រជាពលរដ្ឋ**

## បញ្ជីឈ្មោះសម្រាំងបេក្ខជន

## សម្រាប់ឈរឈ្មោះបោះឆ្នោតជ្រើសរើសប្រធាន អនុប្រធានការិយាល័យប្រជាពលរដ្ឋ

| ល.រ | ឈ្មោះ | ភេទ | អាយុ | សញ្ញាបត្រ(ផ្នែក) | បទពិសោធន៍ការងារ(ឆ្នាំ) |
|---|---|---|---|---|---|
| ក ).មុខតំណែងប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| ខ ).មុខតំណែងអនុប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |

*កំណត់សម្គាល់៖ បេក្ខជនដែលមិនបានជាប់ឈ្មោះនៅក្នុងបញ្ជីសម្រាំងនេះ អាចធ្វើការតវ៉ាជាលាយលក្ខណ៍អក្សរនៅការិយាល័យលេខាធិការក្រុមប្រឹក្សាយ៉ាងយូរត្រឹមថ្ងៃទី......ខែ...........ឆ្នាំ.........។*

........................,ថ្ងៃទី.........ខែ.........ឆ្នាំ.......

**ប្រធានគណៈកម្មាធិការបោះឆ្នោត**

# តារាងបញ្ជីឈ្មោះបេក្ខជន

## សម្រាប់ឈរឈ្មោះបោះឆ្នោតជ្រើសរើសប្រធាន អនុប្រធានការិយាល័យប្រជាពលរដ្ឋ

| ល.រ | ឈ្មោះ | ភេទ | អាយុ | សញ្ញាបត្រ(ផ្នែក) | បទពិសោធន៍ការងារ(ឆ្នាំ) |
|---|---|---|---|---|---|
| ក).មុខតំណែងប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| ខ).មុខតំណែងអនុប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |

ទម្រង់គំរូទី១០៖ គំរូសន្លឹកឆ្នោត(ប្រធាន អនុប្រធានការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត)

# គំរូសន្លឹកឆ្នោត

សូមគូសសញ្ញា (✓) តែមួយប៉ុណ្ណោះ
ក្នុងកូឡោនបោះឆ្នោតគាំទ្រក្នុងជួរបន្ទាត់នៃឈ្មោះបេក្ខជន ដែលអ្នកពេញចិត្ត

| ល.រ | ឈ្មោះបេក្ខជន | ភេទ | អាយុ | រូបថត | បោះឆ្នោតគាំទ្រ |
|---|---|---|---|---|---|
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |